ខេមរភាសា

ប. ណយ

តាមកម្មវិធីសាលារៀនបឋមសិក្សា

# ពាក្យ

ភាសា – អក្ខរាវិរុទ្ធរបស់ពាក្យ

# VOCABULAIRE

## LANGAGE-ORTHOGRAPHE

បោះពុម្ពលើកទី ៤

រក្សាសិទ្ធិ

TOUS DROITS RESERVES

ព. ស. ២៥០១ – គ. ស. ១៩៥៧

Websites: WatKhemaraRatanaram.org or WatKhmers.org

ខេមរភាសា

ជ. ឈុំ

អតីតចាងហ្វាងសាលារៀនព្រះអង្គឌួង (ឡូជាក្ដឺឡាគ្រេ)

# ពាក្យ

## ភាសា–អក្ខរាវិរុទ្ធរបស់ពាក្យ

បោះពុម្ពលើកទី ៤

ការផ្សាយរបស់

បណ្ណាគារ រស្មីកម្ពុជា

រក្សាសិទ្ធិ

TOUS DROITS RÉSERVÉS

ព. ស. ២៥០០ គ. ស. ១៩៥៧

N· 2468

# CONSEIL DES MINISTRES

# PRAKAS

## LE MINISTRE DE L'ÉDUCATION NATIONALE ET DE LA JEUNESSE

Vu la Constitution du Royaume;

Vu le Traité Franco-Khmer en date du 8 Novembre 1949 et ses accords d'application;

Vu le Krâm n· 171-NS du 15 Avril 1946;

Vu le Kret n· 125-NS du 1er Juin 1950;

Vu le Procès-Verbal en date du 4 Août 1950 de la Commission pour Enseignement Primaire Khmer (1re sous-section)

ARRÊTE :

***Article unique.***— Le manuel rédigé en cambodgien par M. CH. CHHUM, Directeur de l'École Doudart de Lagrée, ayant pour titre ពាក្យ ភាសា. អក្ខរាវិរុទ្ធ របស់ពាក្យ», : VOCABULAIRE LANGAGE – ORTHOGRAPHE'', est ajouté à la liste des manuels et publications scolaires dont l'usage est autorisé dans les écoles publiques du Cambodge pour l'année scolaire 1950-1951.

Phnôm-Penh, le 31 Octobre 1950

*Signé :* PITOU DE MONTEIRO.

POUR COPIE CONFORME :

*Pour le Secrétaire Général*
*du Conseil des Ministres et p.o.*
*Le Secrétaire Général-Adjoint*
*Signé:* CHAI-THOUL

POUR AMPLIATION :

*Le chef de Cabinet,*
*Signé:* YEIM-YISINN.

Websites: WatKhemaraRatanaram.org or WatKhmers.org

លេខ១-៥៤២៥ ក.

# រដ្ឋមន្ត្រីក្រសួងសិក្សាធិការនិងយុវបរិយា

មកលោក អ៊ុំ-ឈុំ ចាងហ្វាងសាលាឧត្ដមវិជ្ជាក្រុងភ្នំពេញ

សូមជ្រាប ។

តបសំបុត្រលោកចុះថ្ងៃទី ២៤ កក្កដា គ.ស.១៩៥០

គណៈកម្មការរងបឋមសិក្សាខ្មែរ បានពិនិត្យមើលសៀវភៅ «ពាក្យ» ពីថ្ងៃ ៤ ខែសីហា គ.ស. ១៩៥០ យល់ព្រមបញ្ចូលសៀវភៅ «ពាក្យ» នេះ ទៅក្នុងពួកសៀវភៅសិក្សាតាមពាក្យលោកសុំ ដើម្បីជាប្រយោជន៍សាធារណៈដល់សាលារៀនទូទៅ ក្នុងព្រះរាជអាណាចក្រ ។

ប៉ុន្តែគណៈកម្មការនេះ សុំឲ្យលោកកែតម្រូវពាក្យខ្លះដែលបោះពុម្ពខុស ហើយនឹងពាក្យខ្លះដែលពន្យល់ពុំបានពេញលេញ ដូចមានស្រង់ហើយកែតម្រូវតាមសេចក្ដីកត់ហេតុជាប់មកជាមួយនេះស្រាប់ ។

ខ្ញុំសូមសរសើរចំពោះលោក ដែលមានព្យាយាមតែងនឹងរៀបរៀងសៀវភៅ «ពាក្យ» នេះ ឲ្យកើតឡើងដោយមានប្រាថ្នាចង់លើកដំកើងអក្សរសាស្ត្រ នឹងភាសាជាតិឲ្យបានថ្កុំថ្កើងរុងរឿងតទៅ ។

ភ្នំពេញថ្ងៃទី ២១ សីហា គ.ស. ១៩៥០

ពីទូដឺមុងតេរ

---

ពាក្យខ្លះដែលបោះពុម្ពខុសហើយនឹងសេចក្ដីខ្លះដែលពន្យល់ពុំបានពេញលេញកាលបោះពុម្ពលើកដំបូងនោះបានកែសម្រួលត្រឹមត្រូវហើយ តាមបង្គាប់ពីគណៈកម្មការរងបឋមសិក្សាខ្មែរ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

*Phnom-Penh, 24 Juin 1950*

*Monsieur le Directeur,*

En retour de votre gracieux souvenir : le manuel intitulé «Peak» dont vous avez bien voulu adresser à chacun de nous un exemplaire, nous vous remercions sincèrement et infiniment.

Nous avons pris connaissance de votre livre avec intérêt et nous croyons qu'il nous sera un guide utile et sûr dans l'enseignement du vocabulaire Khmer.

Nous vous renouvelons nos remerciements, Monsieur le Directeur et nous ne manquerons pas de Communiquer la publication de cet ouvrage à tous nos camarades et élèves dans le but de contribuer à votre éclatant succès.

Veuillez agréer, Monsieur le Directeur, l'assurance de nos sentiments les plus respectueux et dévoués.

*P. le Personnel de l'Ecole Doudart de Lagrée.*

NONG-SONN

Websites: WatKhemaraRatanaram.org or WatKhmers.org

*Phnom-Penh, le 30 Juin 1950*

à Monsieur OUM-CHHUM,
*Directeur de l'Ecole Doudart de Lagrée,*
*Auteur du Manuel «PEAK»*

Monsieur,

Ce m'est un très grand plaisir de vous confirmer combien je suis sensible du don d'un livre intitulé «Péak» que vous avez bien voulu me destiner, et je vous en exprime tous mes sincères remerciements.

Étant à la portée de tout le monde, ce manuel rendra de grands services aux maîtres qui peuvent y puiser à volonté ce qu'ils écrivaient et parlaient avec tant de difficultés et hésitations.

Je tiens à vous préciser qu'il est, en notre pays peu d'esprit qui se préoccupe réellement du sort de la littérature. Ainsi, conçu particulièrement en vue de pallier aux erreurs dues à la routine, ce manuel ne présente que d'incontestables avantages, d'autant plus qu'il constitue un guide sûr et précieux pour l'étude du vocabulaire et de l'orthographe Khmers.

Veuillez accepter l'expression de mes meilleurs sentiments.

MORY
*Inspecteur Ajoint*
*Enseignement Kandal,*

Websites: WatKhemaraRatanaram.org or WatKhmers.org

*Phnom-Penh, le 24 Octobre 1950*

à Monsieur OUM-CHHUM,
*Directeur de l'Ecole Doudart de Lagrée*
*à PHNOM-PENH*

Monsieur,

En vous accusant réception d'un manuel «PÉAK» dont vous êtes l'auteur,

J'ai l'honneur de vous prier de bien vouloir trouver ici ma très vive reconnaissance.

Cet ouvrage dont l'édition ne saurait que gagner l'agrément des lecteurs, présente, à mon avis, une très haute valeur éducative. Il est rare de trouver un livre de vocabulaire cambodgien qui, d'une part, s'adapte bien à tous les degrés culturels, et d'autre part, instruit les gens tout en les amusant.

Vous contribuerez, dans une large part, par votre constant souci d'être utile à la nation, au progrès tant du monde scolaire que du public studieux, et vous prendrez, à n'en pas douter, une place honorable parmi les auteurs Khmers au sein du cercle littéraire national.

Veuillez recevoir, Monsieur le Directeur, mes chaleureuses félicitations et mes souhaits de bons succès.

DIEP-PHÉAT
*Inspecteur-Adjoint Phnom-Penh.*

**MINISTERE DE L'ÉDUCATION NATIONALE**

**MINISTRE**

*Le 18 Février 1951*

Mon cher Directeur,

J'ai reçu votre livre et vous félicite chaleureusement de l'avoir rédigé. Il vient heureusement combler une lacune. Il sera pour nos collègues ainsi que pour tous ceux qui aiment l'orthographe exacte un guide précieux.

*Bien cordialement*
HUY-KANTHOUL

Websites: WatKhemaraRatanaram.org or WatKhmers.org

# អារម្ភកថា

សៀវភៅ « ពាក្យ » នេះ គាបឲ្យអ្នករៀនអក្សរនឹងភាសាខ្មែរ ស្គាល់ពាក្យពិតប្រាកដ បេះសរសេរត្រឹមត្រូវតាមអក្ខរៈ មិនសរសេរតាមតែបាន ឬ តាមតែចិត្តឥតមានគោលបារែកនោះឡើយ ។

ពាក្យដែលមានទាំងប៉ុន្មាន គឺខ្ញុំជ្រើសរើសរៀងតាមព្យញ្ជនៈ សំដៅយកតែពាក្យណាដែលត្រូវការប្រើញឹកញយ ហើយមានប្រយោជន៍ជាងគេទៀតផង មកធ្វើជាគោល ព្រមទាំងមានសេចក្ដីអធិប្បាយពន្យល់នូវពាក្យនិមួយៗ អំពីបទវេយ្យាករណ៍ អំពីអក្ខរ-វិរុទ្ធរបស់ពាក្យ ដែលច្រើននាំឲ្យភាន់ច្រឡំ ហើយនឹងរបៀបប្រើពាក្យទាំងនោះបង់ធ្វើជាឃ្លាចំរុះគ្នា បញ្ចូលពាក្យពិបាកផ្សេងៗ ច្រើនទៅទៀត ដើម្បីឲ្យអ្នកសិក្សាត្រង់ត្រាប់បានដោយងាយ ហើយមានពាក្យទំនឹមទំ-នៀមបុរាណជាក់ដោយសង្កាត់ទៀតផង ។

ខ្ញុំមានចិត្តសង្ឃឹមទុកជាមុនថា សៀវភៅបែបនេះដែលពុំទាន់មាននៅឡើយ នឹងពេញចិត្តដល់លោក-អ្នក-នាងជាអ្នកស្នេហាអក្សរនឹងភាសាជាតិជាពុំខាន ។

តុលា គ.ស. ១៩៥០

ឈុំ

Websites: WatKhemaraRatanaram.org or WatKhmers.org

# អក្សរសង្ខេប

| | |
|---|---|
| កិ. | កិរិយាសព្ទ |
| កិ. វិ. | កិរិយាវិសេសន៍ |
| គុ. | គុណនាម |
| ន. | នាម |
| និ. ស. | និបាតសព្ទ |
| ម. បិ. | មើលថា |
| ម. សំ. | មគធៈទីងសំស្រ្កឹត |
| អា. និ. | អាយតនិបាត |

១ ទានសព្ទ

Websites: WatKhemaraRatanaram.org or WatKhmers.org



## ក – ក៏ – ករ

ក= កមនុស្ស – កសាងចេតិយ . កកើតជាភូមិ ។

ក៏= (ធ.ស.) អ្នកក៏ទៅខ្ញុំក៏ទៅ - សើចក៏ដោយយំក៏ដោយ ។

ករ= (ដៃ) - លើកករប្រណម្យ (លើកកំបង់អញ្ជលីសំពះ) ។

ករ– កករទឹក . កករប្រេង - កកូរទឹក កកូរសម្លកកូរ ។

កណ្ដុរ កកេរកការុងនៅក្បែរទ្វារ ។ បើគេកសាងកុដិ យើងក៏ត្រូវតែនាំគ្នាឃោស្នាកសាងព្រះវិហារមួយដែរ ហើយយើងទៅរកលោកទេពនិម្មិត ឲ្យលោកគូររូបទេពប្រណម្យមួយទៀត ។

## កល – កល់ – កលហ

កល= (ម.ថ.កល់) – មាយា – មានពុត – ល្បិច –

ចាយកល – ធ្វើកិច្ចកល – ទាញកលគេ . . .

កល់= (ស៊ែមពីក្រោមឲ្យខ្ពស់ហើយឲ្យស្មើមិនឲ្យល្អៀង) –

កល់ជើងតុឲ្យស្មើ – យកកំណល់ដែលកល់នេះចេញ . . .

Websites: WatKhemaraRatanaram.org or WatKhmers.org



កលហ ឬ កលហ៍= (ម.ថ. កល់ល:ហ:ឬកល់) ជម្លោះ

កើតមានកលហនឹងគ្នា ...។

កាលណាស្រុកកើតកលិយុគ បណ្ដាជនមែនតែនឹងបែកសាមគ្គីពីគ្នា មានឧបាយកលផ្សេងៗ នាំឲ្យមានកលហ៍ពិរោធតែនឹងគ្នាឯង ខ្វះជឿណាស់ខាងមន្តអាគម ខំប្រឹងរៀបកំណល់គ្រូ ដាក់លើហឹងហើយ ថ្វាយបង្គំជាប្រក្រតី ដើម្បីឲ្យខ្លាំងពូកែមានជ័យជំនះ ។

## កា - កាណិ៍ - ការ - ការណ៍

កា= កាខ្នងសំបុត្រ-កាទឹក (បំពង់សម្រាប់ដាក់ទឹក) ។

កាណិ៍= ព្រះកាណិ (គ្រែបៀកស្ដេច) ។

ការ= ធ្វើការ-ការពារ-ការងារ-ការសូត្រ ។

ការណ៍=(ហេតុ,ដំណើរ) ចាស់ការណ៍-មានការណ៍ក្រណាស់ ។

ខ្ញុំមានការណ៍ធំណាស់ ខ្ញុំបានសរសេរសំបុត្រកាខ្នងផ្ញើទៅសុំច្បាប់ឈប់ធ្វើការបានប្រាំថ្ងៃ លុះការណ៍នោះបានសម្រេចហើយ ខ្ញុំនឹងវិលមកធ្វើការវិញ ។ ក្មួយស្រីខ្ញុំវាចេះការងារណាស់ វាការអម្បោះដាក់ខ្នារយ៉ាងស្អាតហើយវាអន្ទងត្បាញធ្វើជាក្រមាគ្រប់ពណ៌ ។

Websites: WatKhemaraRatanaram.org or WatKhmers.org



## កេរ–កេរ្តិ៍ ឬ កិរ្តិ៍

កេរ = និយាយកេរគេ – បង់កេរគោះ (កេរក្លាយមកពីពាក្យកិរ្តិ៍) ។

កេរ្តិ៍ ឬ កិរ្តិ៍ = ស្រែកេរ្តិ៍របស់ខ្ញុំ – កេរ្តិ៍នេះបានមកពីជីដូនជីតា ចែកឲ្យ ៗ កូនអើយកេរ្តិ៍មេបា ចូររក្សាគន់គិតគ្រង......

មាតាបិតាដែលទទួលមរណភាពទៅ តែងតែមានកេរ្តិ៍ទុកឲ្យកូនដូចជាស្រែចំការ គោក្របីជាដើម ហេតុនេះកូនត្រូវខំថែរក្សាកេរ្តិ៍ឲ្យគង់ល្អ បើមាតាបិតាទីទាល់ក្រគ្មានរបស់អ្វីចែកឲ្យ ក៏កូនមិនត្រូវនិយាយសកេរអ្នកមានគុណដែរ ៗ

## កោដិ–កោដ្ឋ–កោត

កោដិ =(ម.ថ.កោត) -១០លាន–១កោដិ–៥កោដិ

កោដ្ឋ = (ជង្រុក – របស់សំរាប់ដាក់សព – ធាតុ) – កោដ្ឋមាស – ហ៊ុនសុវណ្ណកោដ្ឋ (កោដ្ឋមាស) – ទិញកោដ្ឋប្រាក់ដាក់ធាតុ.....

Websites: WatKhemaraRatanaram.org or WatKhmers.org



កោត = (ស្មែនស្មើប) - គោតក្រែង គោតខ្លាច .... ។

សេដ្ឋីនេះកំណាញ់ណាស់ គេពុំសូវគោតញញើតទេ មានសម្បត្តិគោដឃ្លាំងពុំហ៊ានចិញ្ចឹមគោដ្ឋមាសដាក់ធាតុមាតាបិតា ។ សុវណ្ណគោដ្ឋ គឺព្រះមរណនាមនៃព្រះបាទសម្តេចព្រះនរោត្តម ។

## កុំ - កំ - កាំ - កម្ម

កុំ = (និ.ស.) - កុំទៅមក - កុំឲ្យ - កុំពោលពាក្យតាមកំហឹង ។

កំ = កំបាត់កំបាយ - កំណត់ - កំណើត - កំពង់ទឹក - កំពុងដេក - កំពុងបរិភោគអាហារ ។

កាំ = កាំជណ្តើរ - កាំបិត - កាំរទេះ - កាំជ្រួច - កាំរនុះ - កាំភ្លើង - កាំភ្លោះ ។

កម្ម = (ម.ថ.កាំ) ទទួលតាមកម្ម - រងកម្មវេទនា - មានកម្មពៀរនឹងគ្នា - កម្មករធ្វើការឥតស្រាកស្រាន្ត ។

ត្រូវកំបាត់កំបាយកំហឹងកុំចងពៀរក្រែងមានកម្មវេរាតទៅមុខ ។
កាំរនុះខ្ទាំងត្បូងកែជាងគ្រាប់កាំភ្លើងទៅទៀត ។

Websites: WatKhemaraRatanaram.org or WatKhmers.org



## ខណ្ឌ – ខន្ធ – ខាន់ ឬ ខ័ន

ខណ្ឌ = ( សង្កាត់.ប៉ែក , កំណាត់ , កំរិត ) ខណ្ឌជញ្ជាំង – បោះគោល ខណ្ឌព្រំបំការ – ស្វាយខណ្ឌស្ករ ឥតមានខណ្ឌទេ – ព្រះរាជខណ្ឌ ។

ខន្ធ = (កងពួក, គំនរ, សេចក្ដីកំណត់) – ខន្ធ ៥ – ទំលាយខន្ធ (ស្លាប់) រំលត់ខន្ធ (ចូលនិព្វាន) ។

ខាន់ ឬ ខ័ន = ព្រះខាន់រាជ្យ, កើតរោគខាន់បៀត, ខាន់លឿង, ខាន់ស្លាក់, ខាន់ស្លា ។

ផ្ទះនេះគេបានចែកឲ្យកូនពីរនាក់ ខណ្ឌពាក់កណ្ដាលទីជញ្ជាំងក្ដារយ៉ាងសំខាន់ ។ រូបមនុស្សយើងមានខន្ធប្រាំ ព្រះខាន់រាជ្យដំកល់ទុកនៅព្រះបរមរាជវាំង ។ បុរសប្ដីប្រពន្ធនេះបានរៀបការគាពាហ៍ពិពាហ៍មានខាន់ស្លាពេញច្បាប់ ។ នៅខាងមុខប្រាសាទព្រះខាន់មានស្វាយខណ្ឌស្ករមួយដើម ។

មនុស្សនេះ កើតរោគខាន់លឿងយូរឆ្នាំណាស់មកហើយ នាំឲ្យខ្លួនទាំងឡាយទ្រុឌទ្រោមទាំងអស់ ពេទ្យចំណានមានជំរះសំខាន់យ៉ាងណាក៏មើលពុំជា ។

Websites: WatKhemaraRatanaram.org or WatKhmers.org



## ក នឹង ខ

អក្សរ ្ន-្ម-្ល-្ស- ទាំង ៤ តួនេះផ្ញើជើងនឹងអក្សរ ក នឹង ខ បានដូចគ្នា ហេតុនេះត្រូវចំណាំ ដើម្បីកុំឲ្យច្រឡំរបៀបផ្ញើជើងនឹងអក្សរពីរតួខាងលើនេះ ។

ក្ន=ក្នក់ក្នាញ់-ក្នុង ...

ខ្ន=ខ្នល់ខ្នើយ-ដាក់ខ្នោះ-ខ្នោសកោសដូង ...

ក្ម=កូនក្មួយ-ម្តាយក្មេក-ក្មេងក្មាង ...

ខ្ម=ខ្មងត្រី-វេញខ្មាញ់-ខ្មាសអៀន-ចិត្តខ្មាំង ...

ក្ល=ក្លាហាន-ក្លៀវក្លា-ក្លិនក្រអូប-ក្លើប្រាក់-ក្លែងក្លាយ ...

ខ្ល=ខ្លារខិន-ខ្លាបខ្លួន-ខ្លែងហើរ-ខ្លៅល្ងង់ខ្លះ ...

ក្ស=មហាក្សត្រិយ៍-ក្ស័យជីវិត-ក្សិណក្ស័យ-ក្សេមក្សាន្ត
ទឹកក្សីរ-ក្សេត្រាធិការ ...

ខ្ស=ខ្សត់ខ្សោយ-ដីខ្សាច់-ខ្សឹកខ្សួលអួលព្រះទ័យ-ខ្សឹបខ្សាវ-ខ្សែក្រវាត់-ជក់ខ្សៀ នាំគ្នាខ្សឹបខ្សៀវ ...

Websites: WatKhemaraRatanaram.org or WatKhmers.org



ម្ដាយក្មេកចូលទៅក្នុងផ្ទះ ហៅក្មួយស្រីឲ្យយកពូកខ្នល់ខ្នើយទៅហាលថ្ងៃ ៗ ចូរកុំខ្មាសអៀននឹងការសិក្សា រៀនបិត្តក្ដាហានវេលាមានអាសន្ន ៗ ក្ដីខ្ញុំបានធ្វើខ្លែងបង្ហើរមួយថ្វាយព្រះមហាក្សត្រិយ៍ ៗ មនុស្សខ្សត់ខ្សោយពុំសូវបានសុខក្សេមក្សាន្តប៉ុន្មានទេ ៗ

---

## ពាក្យទំនឹមទំនៀមបុរាណ

- ចេះមកពីរៀន មានមកពីរក ៗ
- តក់ៗពេញបំពង់ ៗ
- សន្សឹមកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា ៗ
- រត់ឥតអំពើ ដើរអំណត់ចំរើនជាង ៗ
- បើខឹងឲ្យខំអត់ បើខ្សត់ឲ្យខំរក ៗ
- ដើយរ៉ាស្អក ទុនរ៉ាដាក់គ្រាប់ ៗ
- ចង់ពិសាឲ្យរកអន្ទក់ ចង់ស្រណុកឲ្យនឿយពីក្មេង ៗ
- ក្រកៗអ្នកស្រុកមើលងាយ រលាស់គូថខ្ចាយមានទុកមានកាន់ ៗ
- ដូងមួយធ្លាយមានតក់មាននាឡិ ៗ
- សំដីជាឯក លេខជាទោ អក្សរជាត្រី ៗ
- ស៊ីព្រោះលោះកម្លាំង ៗ

Websites: WatKhemaraRatanaram.org or WatKhmers.org



- មនុស្សគេយកសំដី ដំរីគេយកភ្លុក ។
- សាច់មិនបានស៊ីយកឆ្អឹងព្យួរក ។
- ពុតគ្រូកុំត្រាប់ ច្បាប់គ្រូឲ្យយក ។
- អាគមផ្សំអាយុ ។
- ក្លូតនៅហោរ ហោរនៅជាន់ ។
- បេះដប់ពុំស្មើនឹងប្រសប់មួយ ។
- ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ ។
- សីលជាស្ពាន ទានជាស្បៀង ។
- រើសដៃ ផ្ដៃផ្អែត ។
- កាប់បំពង់រង់ទឹកភ្លៀង ។
- កុំបោះសន្ទូចបំលងក្អំ ។

**គ – គរ – គភ ឬ គ៌ភ៌**

គ = មនុស្សគ – ប្រាក់គ (ឥតសូរ) ។

គរ = ដើមគរ – សម្ដីគរ = យកគរញាត់ខ្នើយ – គរឲ្យខ្ពស់ធ្វើជា
គំនរ – ប្រាក់មានគរគោក...

Websites: WatKhemaraRatanaram.org or WatKhmers.org



គតិ= (ម. ថ. គ័រ) ស្រីមានគតិ-ទ្រង់គតិ ។

ខ្ញុំឃើញស្រីគម្នាក់មានគតិផង ដើររើសផ្លែតរទុំតាមមាត់អូរគេ ។

## គន់-គុណ-គុន

គន់= គន់មើល-គយគន់-គន់គូរ-បង្គន់ ឬ បាំងគន់....

គុណ= លេខគុណ-គុណធម៌-គុណមាតាបិតា-គុណនាម....

គុន= ហាត់គុនឲ្យស្ទាត់-គុនដាវ-គុនដំបង.....

មានគ្រូម្នាក់ចេះគុនដាវ គុនដំបង ហើយចេះទាំងគន់គូរមើលគូព្រេងទៀតផង គ្រូនេះមានគុណលើគេស្ទើរតែគ្រប់គ្នា ។

## គូ-គូរ

គូ= ន. ស្នាមគ្រោះព័ទ្ធជុំវិញបន្ទាយ ឬ វាំង ។ ទៅមុជទឹកគូ....

គូ= ន. ចំនួនពីរផ្ទឹមគ្នា-មួយគូ-ព្រាបមួយគូ-គូកម្ម....

គូរ= កិ. ធ្វើឲ្យកើតជាគំនូរដំណាងរូបរាង សរសេរ-គូររូប-គូរគំនូរ

កាលពីថ្ងៃអាទិត្យមុនខ្ញុំបានទៅមុជទឹកគូ ឃើញតាចាស់

ម្នាក់កំពុងតែគន់គូររកគូព្រេងឲ្យនាងក្រមុំម្នាក់អង្គុយនៅមាត់គូ ហើយគាទាយថាគូស្រករនាងឯងជិតដល់ហើយ ។

## គំ - គុម្ព - គុម ឬ គុំ

គំ= គំនាប់ - គំនិត - គំនូរ - គំនូសគូស - គំនុំ - គំពមគំពេះ...

គុម្ព= គុម្ពឈើ - គុម្ពឫស្សី - គុម្ពោត - ស្លឹកគ្រៃមួយគុម្ព...

គុម ឬ គុំ= គុំគួន - គុំព្យាបាទ - គុំបំផ្លាញ... ។

មនុស្សគ ឈរក្រោមដើមគរ ក្បែរគំនរអុស ។ គ្រូនេះបេះគន់គូរមើលរាសីបូកផ្សំថ្ងៃខែគុណលេខរហ័សណាស់ ។ បុរសនោះមានគំនិតអាក្រក់គុំព្យាបាទគេ កាន់កាំបិតទៅពួនសម្ងំនៅប្របគុម្ពឫស្សី ។

## កៀប - គាប

កៀប= រិតដោយដង្កៀប, ក្ដាមកៀបដៃ....

គាប= រិតដោយឃ្នាប ឬ គំនាប - គាបគ្នាត - គាបមនុស្ស...

ចូរកុំលេងនឹងសត្វណាដែលមានដង្កៀបខ្លាចក្រែងវាកៀបដៃ ។

Websites: WatKhemaraRatanaram.org or WatKhmers.org



គេយកឃ្លាបតាមពោរស្លរយកបម្លើយ ជួនកាលគេយកដំបៀត តៀត ត្រៀបៀកឬគៀបសាច់ក៏សឹងមាន ។

## ក្រ – គ្រ

អ្នកសរសេរច្រើនច្រឡំពាក្យដែលចេញពី „ក្រ និង គ្រ„ ពីព្រោះធ្លាប់និយាយខុសខ្សល់អក្សរតាំងពីដើមមក លុះសរសេរក៏សរសេរតាមសព្ទដែលនិយាយនោះ ។

ក្រ= ក្របសៀវភៅ-ក្រាសសិតសក់-ក្រាស់ស្តើង-
ក្រិត្យក្រម - ក្របខ្នារ - សត្វក្របួ - មុខក្រៀមក្រោះ-
ក្រេវក្រោធ - ក្រោលក្របី...

គ្រ= គ្របពាង - គ្រាប់ឈើ - គ្រោះថ្នាក់ - ស្លឹកគ្រៃ...។

ត្រូវយកក្រដាសក្រាស់ធ្វើក្របសៀវភៅការពារកុំឲ្យឆាប់រហែក ។ កាលណាសិតសក់រួចហើយ ត្រូវទុកដាក់ក្រាសទឹងស្និតក្នុងប្រអប់គ្របឲ្យជិតកុំឲ្យធូលីចូលបាន ។ បងខ្ញុំមានគ្រោះថ្នាក់ក្រាស់ក្រៃ គាពោរបក្រៃបចូលលួចក្របីអស់ពីក្នុងក្រោល គាត់ក្រេវក្រោធកើតទុក្ខមុខក្រៀមក្រោះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org



## ង - ងរ - ងា - ងារ

ង = ទូកង - ពត់ឈើឲ្យងបុង - ក្អែកងងឹត - ងងុយដេក.....

ងរ = (សំដែងអាការមាយា) នាំងរ ស្រីងរច្រើន...

ងា = ងាដៃងាជើង - ងាដៃជន្ទលេង...

ងារ = (មុខងារ) ការងារ - ងារមន្ត្រី ដីមួយងារ - ស្ងួនងារ...។

អ្នកអង្គុយលើក្បាលទូកង ងាដៃទៅមុខទៅក្រោយ ខ្វះប៉ុនប្រសប់ បានងារការក្នុងរបៀបអុំប្តូរដៃទូកនោះផង ។ ស្រីនេះចិត្តសាវា៉ ងរចុះងរឡើង ស្ងួនងារឲ្យគេពល់តែឆ្នាំ ។

## ប - បរ

ប = ឆ្នាំប (ឆ្កែ) បឈើ (ពុះឈើ)....

បរ = បរព្នោះទៅ - បរយាត្រា - បរបានទន្ទា - បរណៃ......

កាលពីឆ្នាំប ព្រះមហាក្សត្រិយ៍ទ្រង់បានបរលីលាទៅកាន់ប្រទេស លាវ ដើម្បីបរបាការណ៍សុខទុក្ខក្នុងព្រះនគរ ។

Websites: WatKhemaraRatanaram.org or WatKhmers.org



## ចារ-ចារុ៍-អាចារ-អាចារ្យ

ចារ= ចារសាស្ត្រា ដើមចារផ្កាក្រហម សុភាចារបុរស ធ្វើចំណារចាររបស់....

ចារុ៍= (ម.ថ.ពា) ចារុ៍មាស ចារុ៍ប្រាក់ បុរណាពាក់អានចារុ៍....

អាចារ= មានអាចារល្អ (បុគ្គល – មារយាទ – ចរិយា)

អាចារ្យ= អាចារ្យវត្ត – អាចារ្យយោគី....

គេចារសាស្ត្រានឹងដែកចារ ។ អ្នកចំណារចាររបស់ព័ទ្ធជុំវិញសួនច្បារ ។ នារីនេះពាក់ចារុ៍មាស មានអាចាររម្យទម ។ លោកសុភាចារបុរសបានគេគោះហៅអាចារ្យយោគី អំពីបំភ័យអ្នកស្រុកឲ្យយកតែអុសចារបូជាខ្មោច ។

## ចិត-ចិត្ត-ពិចិត្រ ឬ វិចិត្រ

ចិត= ចិតខ្មៅដៃ–ចិតក្របក–ចិតនឹងកាំបិតមុត

ចិត្ត= ចិត្តល្អ ចិត្តមានអារម្មណ៍ ចិត្តយោរយៅ....

Websites: WatKhemaraRatanaram.org or WatKhmers.org



ពិចិត្រ ឬ វិចិត្រ= ដែលរំលេចឬផ្លាស់ក្បាច់ចេនាឬល្អប្លែក)

ក្បាច់វិចិត្រ – ទំរិចិត្រឲ្យល្អប្លែក...។

កុមារនេះ ខំយកចិត្តទុកដាក់ទីនការសូត្ររៀនណាស់ ដល់ពេល គួរគំនូរក៏យកខ្មៅដៃដែលចិតទុកយ៉ាងស្រួចមកគូរឲ្យល្អវិចិត្រ ។

| ពោត–ពោធ |
|---|

ពោត= ប្រាំងពោត – ដីពោត – ចំណោតភ្នំ...

ពោធ= សួរពោធ - សេចក្តីពោធ - ដោះចំណោធដែលគេពោធ..

មានអ្នកប្រាជ្ញម្នាក់សួរពោធថា ពីព្រោះអ្វីបានជាប្រាំងទន្លេមាន កន្លែងខ្លះពោតចុះទៅគំពង់ពុំបាន កន្លែងខ្លះទេរចុះឡើងបានដោយងាយ ចូរដោះស្រាយចំណោធនេះឲ្យបានពិស្តារ ។

| ប្រាង–ប្រាំង–ជ្រាំង |
|---|

ប្រាង= បន្ទាប្រាង–សម្រាស់ឬសប្រែងប្រាង...

ប្រាំង= ប្រាំងទន្លេ – ប្រាំងសមុទ្រ – ប្រាំងពោត – ប្រាំងទេរ

Websites: WatKhemaraRatanaram.org or WatKhmers.org



ជ្រាំង = កើតជ្រាំងពេញមាត់ - ជ្រាំងខ្ទរស្មៃ... ។

តាមប្រាំងទន្លេ អ្នកនេសាទត្រីដោតសម្រាស់ប្រូងប្រាង ។ ទារកនេះកើតជ្រាំងពេញអណ្ដាតសក្បុសដូចដីផ្ដនៅមាត់ប្រាំងទន្លេកំពង់ឆ្នាំង ។

| ឆ្មា - ឆ្មារ |
|---|

ឆ្មា = ឆ្មាស្រុក - ឆ្មាព្រៃ - ឆ្មាជាសត្វចតុប្បាទសត្រូវនឹងកណ្ដុរ... ។

ឆ្មារ = ខ្សែឆ្មារ - សរសៃអម្បោះឆ្មារ - ក្រូបឆ្មារ... ។

ឆ្មាជាសត្វចតុប្បាទចាប់កណ្ដុរបរិភោគជាអាហារ ពេមពំឆ្មារទន់ដូចសម្ពីកបាស ។

| ឆ្លាត - ឈ្លាស - ឆ្លៀត - ឈ្លៀស |
|---|

ឆ្លាត ឬឈ្លាស -គុ. (ប៉ិនប្រសប់-ស្ទាត់) ប្រាជ្ញាឆ្លាតឬឈ្លាស-មនុស្សឈ្លាសឬឆ្លាត- ឈ្លាសវៃ...

ឆ្លៀត - កិ. (រំលែកពេលឬលួចរបក់ធ្វើកិច្ចការអ្វីៗ) ឆ្លៀតធ្វើការផ្សេងទៀតផង - ធ្វើការរាជការផង ឆ្លៀតធ្វើជំនួញផង ។

Websites: WatKhemaraRatanaram.org or WatKhmers.org



ឈ្លៀស– កិ. ( ស្កាត់កេណ្ឌយកមនុស្សឬសត្វមកប្រើជាពលការបណ្ដើរស៊ិន ) ឈ្លៀសមនុស្ស ( ស្កាត់កេណ្ឌមនុស្ស ) ឈ្លៀសគោរទេះ...

មានមេឃុំម្នាក់វ័យនៅក្មេង ធ្វើការពលការខ្លាំងពេកណាស់ ហើយធៀតធ្វើការងាររចិញ្ចឹមជីវិតខ្លួនឯងផង បើមានការធ្វើបុណ្យកឋិនម្ដងៗ ដោយប្រញឹកប្រញាប់ មេឃុំឈ្លៀសអ្នកស្រុកឲ្យលើកថ្នល់ភ្លាមៗ

## ឆ្ងៀង–ឈ្ងៀង

ឆ្ងៀង = ន. (ទីទៃពីស្ដាំ) ខាងឆ្វេងដៃ មនុស្សឆ្វេង (មនុស្សធ្វើការអ្វីៗមិនចុះបែប)

ឈ្ងៀង = គុ. (ថ្លាជ្រះឥតមន្ទិល) ទឹកថ្លាឈ្វេង... ។

កិ. ឈ្វេងយល់ (រំពឹងគិតយល់ដោយប្រាជ្ញាជ្រៅជ្រះ) ។

មនុស្សមានប្រាជ្ញាឆាប់ឈ្វេងយល់ការណាស់ បើមានការណ៍អ្វីកម្រ ចរំពឹងគិតដោយហ្មត់ចត់ទើបបានធ្វើ មិនធ្វើបំពាក់បំពានខុសបែបបទដូចមនុស្សឆ្វេងនោះឡើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org



## ជរ – ជូរ – ជួ – ជួរ

ជរ= ហួលជរ–ជរជាយ–សំពត់មានជរ

ជូរ= អម្ពិលជូរ–សម្ជូរ....

ជួ= មនុស្សជួ–ជួជន់–អាក្រក់ជួជាតិ....

ជួរ= ឈរជាជួរ - ជួរពោត - ជួរជំហួរ... ។

សម្លណាមានរសជាតិជូរ ហៅថាសម្ជូរ ។ ឪពុកក្មេកឃើញកូនប្រសាស្លៀកហួលជរដើរលេង ឥតមានគួរសមនឹងញាតិសន្តាន ក៏ត្មះតិះដៀលថា អានេះជួជន់ណាស់ ប្រហែលជាកាត់ទៅជួរខាងម្តាយវា ។

## ជុំ – ជំ – ជាំ

ជុំ= ដើរមួយជុំ – ប្រទក្សិណបីជុំ – ទីប្រជុំ...

ជំ= ជំទាវ – ជំនន់ – ជំនួញ – ជំនុំជំរះ – សំពត់ជំនិ...

ជាំ= មុខជាំ – ក្រហមជាំ – ដីជោកជាំទឹក... ។

វេលានោះ គេប្រជុំគ្នានៅសាលាស្រុក លុះរាស្ត្របានមកជួបជុំគ្នា

Websites: WatKhemaraRatanaram.org or WatKhmers.org



ហើយទើបគេជំនុំគ្នាពីផ្លូវជំនួញផ្សេងៗ ។ ទៅក្រុមជំនុំជំរះរឿងជំទប់ជុំ ដែលគេហ៍យជាំមុខ ។

## ញុះ - ញោស - ញោះ

ញុះ= ញុះញង់ – ញុះញយ ៗ...

ញោស= ស្វាយទុំញោស – ចាស់ញោស – ស្ដីដេរ

បន្ទោសញោសពេកណាស់...

ញោះ= ញោះមួយដំបង – ញោះមួយម៉ាត់ប្រឡាតតួន... ។

កុំញុះញង់គេឲ្យឈ្លោះគ្នា កំហឹងជ្រុលញោសពេកនាំឲ្យមានទុក្ខធំ ។ មនុស្សចិត្តស្រាល បើគេញោះតែមួយម៉ាត់ខឹងប្រលោតមួយរំពេច ។

---

## ពាក្យទំនឹមទំនៀមបុរាណ

– គេខុសកុំអាលអរ គេសាទរកុំអាលអួត

– ជាងមិនកើតទៅបន្ទោសដែក

– នៅស្រុកឲ្យស្រាស់បន្ទា អារសាច់ជូនខ្លាទើបនៅស្រុកបាន

– ឆ្កែខាំឲ្យរកម្ចាស់ គោឆ្កើះឲ្យរកនាយ

Websites: WatKhemaraRatanaram.org or WatKhmers.org


- នៅផ្ទះម្ដាយទីទៃ ទៅព្រៃម្ដាយជាមួយ
- ស្អប់កុំឲ្យផាញ់ ស្រឡាញ់កុំឲ្យខ្ចី
- ទឹកជោរត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី
- គ្នាច្រើនអន្សមខ្លោច គ្នាដូចស្រមោចអន្សមឆៅ
- រហ័សតែមាត់ ត្រគាកស្ងាប់ស្ដូក
- ឮផ្គរកុំអាលចាក់ទឹកចោល
- កុំយកមេឃទ្រាប់អង្គុយ
- បើមិនជួយបូកជួយបែរ កុំយកជើងរាទឹក
- ញ្ញើនៅថ្នក់ ទំពក់នៅដៃ
- គោកៗសឹកតែមាត់ត្រជោក ឆ្អែតតែពោះក្របី
- ឈើកោងវល្លិព័ទ្ធ មនុស្សសាត់ព្រាត់កុំយកជាគ្នា
- គោដំបៅខ្នង ក្អែកហើររំលង រំសាយកន្ទុយ
- ក្អែកមួយជាក្អែកដប់
- ទូកបែកជាទូកគត់ ទូកកំបុតជាទូកង
- ទូកទៅ កំពង់នៅ
- ធ្វើស្រែឲ្យមើលស្មៅ ទុកដាក់កូនចៅឲ្យមើលផៅសន្តាន
- ឃ្លោកលិច អំបែងអណ្ដែត

Websites: WatKhemaraRatanaram.org or WatKhmers.org


## ជ – ជ៏ – ជ័រ

ជ = ទូកជ កំពង់ជ–ជូនជ

ជ៏ = ទ. ទ្រព្យដ៏ប្រសើរ – គុណដ៏ឧត្តម–ធម៌ដ៏បវរ

ជ័រ = បូសជ័រ–ដំណោជ័រ រកស៊ីតាំងត្រជ័រ ។

ពាណិជនេះមានធនធានដ៏ប្រសើរ បានជិះទូកជទៅស្រុកគាត់ ត្រូវខ្យល់ព្យុះបោកលិចទូក ទំប្រឹងត្រដរហែលទាល់តែដល់គ្រើយ ។

## ជុស – ជុះ – ខុស

ជុស = ជុសក្អែល–ជុសលាង ជុសខាត់–ជុសធ្មេញនឹងច្រាស់...

ជុះ = ស្រូវជុះពន្លក–ដីជុះខ្ពស់–រកស៊ីជុះដាល....

ខុស = សរសេរខុស–ធ្វើលេខខុស–សេចក្ដីខុស ។

ខុសហើយឯង ហេតុអ្វីបានជាយកគោទៅបង់ឲ្យត្រជុសគ្នាលើ ដំណាំកំពុងតែដុះល្អខ្ទបខ្ទីអស់ ។

Websites: WatKhemaraRatanaram.org or WatKhmers.org



## តាំងបិ

ចូរប្រយ័ត្នផ្ញើជើងអក្សរ «្ប-្ល» ទីងតួអក្សរ «ត-ថ» ។

ជើង «្ប» ត្រូវនៅក្រោម «ត» មិនត្រូវនៅក្រោម «ថ» ទេ ៖

…ាញ - ត្បាត្របៀក - ត្បាល់កិន - ត្បុតត្រី - ត្បុលបូលខាងត្បូង -

…ន់ខ្មើយ - ម្ចាស់ជីវិតលើត្បូង - ត្បូងពេជ្រ . . .

ជើង «្ល» ផ្ញើទីងតួអក្សរ «ត» មានពាក្យតិចណាស់ ដូចជា ៖

…ករបាំ - រាលត្លឹងត្លុវឥតព្រៃ ក្របត្លុងមូលត្លុំ ។ ក្រៅពីនេះជើង «្ល»

ផ្ញើទីងតួ «ថ» ទាំងអស់ ៖ ថ្លស់ថ្លោយ - ទឹកថ្លា - ថ្លាងធំ - ថ្លឹងមាស -

…កត្រពាំង - ថ្លៃថ្នូរ - កូនថ្លោស - ថ្លោសបិត្ត . . .

អក្សរ «អ» ត្រូវនៅក្រោម «ត» ៖ រងត្អឹង, ត្អូញត្អែរ, កូនកេងត្អែក

## បេះ - បំពោះ - ត្រិះ - តិរិះ - ជិរិះ

បេះ= បំពោះ មនុស្សបេះ, កុមារនេះមានបំពោះគ្រាន់បើ . . .

ត្រិះ - តិរិះ - ជិរិះ= ទ្រង់ត្រិះរិះ, ទ្រង់ព្រះដំរិះ, (ទ្រង់គិត) លោក

មានដំរិះល្អ (មានសេចក្ដីរិះគិតត្រូវ) . . .

Websites: WatKhemaraRatanaram.org or WatKhmers.org



មនុស្សណាមិនចេះអក្សរគេទុកដូចជាមនុស្សខ្វាក់ ។ ត្រូវខំប្រ

. ស្វែងរកចំណេះវិជ្ជាទាន់វ័យនៅក្មេង . . .

## គ្រៀប - ទ្រាប

គ្រៀប= គុ.វិ. ដែលដេរជាសជាយមានរបៀប ។ ឈរគ្រៀ

មើលទៅឃើញគ្រៀប - មនុស្សឈរគ្រៀបគ្រា . . .

ទ្រាប= ន. ឬកិ. ទ្រាបបាយផ្អែម ទ្រាបល្ង ។ ទ្រាបស

ពីលើ - ទ្រាបលើស្នា ។

មានគេធ្វើបុណ្យគ្រៀបគ្រាក្នុងវត្ត មានសិស្សលោកម្នាក់ដើរ

គេដួលទ្រាបលើសម្ទីងទ្រាបបាយដែលគេប្រគេនលោកកំពប់អស់

## ថ្មារ - ថ្មើរ

ថ្មារ= ពេល កាល សព្វថ្ងៃច្រើនប្រើ "ថ្មើរ" វិញ ថ្មើរមានបេ

យប់ថ្មើរណេះហើយទៅពុំបានទេ

ថ្មើរ= ថ្មើរជើង ទាហានថ្មើរជើង (ពេលដើរដោយជើ

ថ្មើរព្រៃបរបាញ់សត្វក្នុងព្រៃក្បា . . . ។

Websites: WatKhemaraRatanaram.org or WatKhmers.org



មកដល់ទីនេះចោរម៉ាន អ្នកឃើញពលចោរដើរមកហើយឬនៅ ។

**ទូ-ទូរ-ទា-ទារ**

ទូ= ទត្រងទឹកភ្លៀង, ទឹកហូរតាមទស័ង្កសី....

ទូរ= (ដេរស្តីបន្ទោស) កូនសិស្សខ្ជិលគ្រូទរសន្ទឹក...

ទា= សត្វទាឈ្មោលញី, ទាញីទទះស្លាបហែលទឹក

ទារ= ទារប្រាក់ថ្លៃផ្ទះ, ទារប្រាក់ថ្លៃទា, ជំទប់តឹងទារប្រាក់

ពន្ធថ្លៃដី ។

ប្តីទរប្រពន្ធសន្ទឹក ពីព្រោះស្តោះទឹកមាត់ទៅលើទត្រងទឹក ។

ឹកស្អែកខ្ញុំទៅទារប្រាក់ថ្លៃទាអំពីជស្ងៀទា ។

**ទាន - ទៀន**

ទាន= ធ្វើទាន - ឲ្យទានបាយសម្ល - សូមទានមេត្តាប្រោស...

ទៀន= ទៀនធូប - អុជទៀនជ័យ - លញ់ទៀនវស្សា.....

លោកតាគាត់ទៅសមាទានសីលឯវត្ត ដៃកាន់ជើងពានមានផ្កាទឹន

ទៀនធូប ។

Websites: WatKhemaraRatanaram.org or WatKhmers.org


## ទស់ - ទោស - ទោះ

ទស់= (ពាក្យទប់) ទប់ធ្ងន់ទស់ផ្ទុក ទស់ទប់ឲ្យជាប់ . . . . .

ទោស= ទោសធ្ងន់ - កាត់ទោសសម្លាប់ - ទោសពៃរ៍ - សូមអភ័យទោស . . . . .

ទោះ= ទោះល្អក៏អាក្រក់ក្តី - ទោះបីខុសត្រូវដូចម្តេច . . . . . ។

ជនល្មើសធ្ងន់ត្រូវមានទោសពិន័យជាប្រាក់មួយពាន់រៀល អំពីប្រព្រឹត្តខុសទីនិបាតិ ។ សេចក្តីនេះទោះបីលើសលស់ធ្ងន់ធ្ងរយ៉ាងណា សូមមេត្តាអភ័យទោស ។

## ទាប - ទៀប

ទាប= ដីទាប - ពន្ធទាបទ្រនាប់ - កិរិយាពបទាប . . . .

ទៀប= ទៀបទីដល់ - ទៀបក្លី - ទៀបកោះ - ផ្ទុះទៀបទុំ - ទៀបដាក់ចំណីអាហារ . . . . ។

Websites: WatKhemaraRatanaram.org or WatKhmers.org



កុមារីនេះមានកិរិយាសុភាពរាបសាបគួរសមណាស់ បានផ្លែទៀបទុំដាក់កន្ទ្រកទៀបស៊ីទ្វិកណ្ដៀតយកទៅជូនអ្នកគ្រូបង្រៀន ។

## ទ្រព្យ - ទ្រាប់ - ត្រប់

ទ្រព្យ = ន. វត្ថុ-ធនធាន-សម្បត្តិ ។ ថែទាំទើបគង់ទ្រព្យ ។

ទ្រាប់ = កិ.-រង-កលពីក្រោម ។ ទ្រាប់ធ្វើជាទ្រនាប់......

ត្រប់ = ន.-ឈ្មោះដំណាំ មានផ្លែបរិភោគជាបន្លែម្ហូបអន្លក់

ត្រប់ពុតលំញង - ត្រប់ក្រាមមាស...... ។

យាយត្រប់គាត់មានទ្រព្យសម្បត្តិច្រើន គាត់យកស្លឹកចេកទ្រាប់បាតកញ្ជើដាក់ផ្លែត្រប់ពេញ ទូលទៅលក់ឯផ្សារ ហើយគាត់ទិញបានត្រីកន្ធុបមួយគូ ។

## ធន - ធន់ - ធុន

ធន = ម.ថ.ធន៌- ទ្រព្យសម្បត្តិ-ធនធាន-ទ្រព្យធន

(កុំសរសេរយ៉ាងនេះ៖ ធន់ធាន)....

Websites: WatKhemaraRatanaram.org or WatKhmers.org



ធន់ = (ទ្រាំ, អត់, ធ្មត់, ស៊ូ) ធន់ជម្ងឺ – ធន់រងា...

ធុន = (បែបយ៉ាង, កំណើតដូចគ្នា) ឡានមួយធុន – កែវមួយធុន – មនុស្សមួយធុន... ។

ពាណិជម្នាក់មានទ្រព្យធនជាច្រើនណាស់ ប្រឹងធ្វើការមិនដឹងយប់-ថ្ងៃ ធន់ក្តៅធន់ត្រជាក់ មនុស្សធុននេះ ពុំសូវមានច្រើនទេ ។

**ធុំ – ធំ**

ធុំ = (ក្លិន)– ធុំក្រអូប – ធុំអាក្រក់ – ធុំក្លិនសាយ...

ធំ = (ទីទៃពីតូច) ផ្ទះធំទូលាយ – សាលាធំ – ឪពុកធំ – ធំប្រុសធំស្រី ។

កាលប្អូនខ្ញុំនៅតូចវាស្មោកគ្រោកណាស់ ទោះអាវវាក៏ធុំក្លិនអសោច លុះដល់វាធំឡើង ចូលទៅរៀនឯសាលាវាស្អាតជានិច្ច

**ធប់ – ធព្វ**

ធប់ = ស្ទួនខប់ – លើកទំនប់ទប់ទឹក...

Websites: WatKhemaraRatanaram.org or WatKhmers.org



នព្វ = (ប្រាំបួន – មាសនព្វគុណ (មាសទឹក៩) – នព្វគ្រោះ (ឈ្មោះផ្កាយគ្រោះ៩) នព្វន (វិជ្ជាលេខមាន៩)

លេខនព្វន – ក្បួននព្វន.... ។

មានអ្នកស្រែម្នាក់កំពុងតែលើកទំនប់ទប់ទឹក ឃើញកុមារម្នាក់ដើរកដិតក៏សួរថា នាងឯងរេះក្បួននព្វន្តឬទេ បើចេះចូរគេថ្ងៃស្មូនទប់១៥ត្រូវជាប៉ុន្មានរៀល បើស្មូន ២ ថ្ងៃ ២៤រៀល ។

## ន្ទូរ – នៅ

ន្ទូរ = (ម.ឋ.នៅ) ខិ. នឹងហើយនឹង: មាតាបិតានឹងបងប្អូនទូរមាមីងទាំងអស់ ។

ឝា.ខិ. (ពាក្យប្រាប់ដំណើរសម្រេចអំពើដែលគេត្រូវធ្វើ) នឹងបាននូវផលល្អ–អ្នកនឹងសម្រេចនូវវិជ្ជាដ៏ប្រសើរ សិស្សប្រព្រឹត្តនូវអំពើល្អ... ។

នៅ= កិ. នៅផ្ទះនៅក្នុងបន្ទប់ – អស់ហើយឬនៅ – នៅឡើយ ។

សិស្សទាំងឡាយ ចូរអ្នកខំប្រឹងសូត្ររៀន ឲ្យបានសម្រេច នូវចំណេះវិជ្ជាដ៏ប្រសើរទាន់ខ្លួនអ្នកនៅក្មេង ។

Websites: WatKhemaraRatanaram.org or WatKhmers.org



## ប៉ា – ប៉ារ – ប៉ិត – ប៉ិទ

ប៉ា = ផែប៉ា – ហៃប៉ា – មេប៉ា – គោប៉ា – ក្របីប៉ា...

ប៉ារ = ប៉ារដីក្នុងរណ្ដៅ – ក្មេងប៉ារយំយប់..,

ប៉ិត = ប៉ិតផ្ដៅ – ប៉ិតឈើស្រួច – ប៉ិតស្រោ...

ប៉ិទ = ប៉ិទទ្វារ – ប៉ិទមាស – ប៉ិទមុខ ប៉ិទប៉ាំង ។

ឪពុកហៅប៉ា មានគោប៉ាមួយធំ ខ្លួនជំប៉ារ យកទៅលក់ឲ្យប៉ិនប៉ិតស្រោ នៅទន្លេប៉ិទជិតផ្សារកំពង់ចាម ។

## ប៉ូ – ប៉ូរ – ប៉ូព៌

ប៉ូ = បងប៉ូ – សក់បងប៉ូ...

ប៉ូរ = ប៉ូរប៉ាច់ – និយាយប៉ូរប៉ាច់ប្រាប់គេ...

ប៉ូព៌ = ទិសបូព៌ឬទិសបូព៌ា (ទិសខាងកើត)

កាលពីថ្ងៃអាទិត្យ មានកុមារីម្នាក់ដើរមកពីទិសបូព៌ បងប៉ូសក់យ៉ាងស្រស់ មុខរីករាយហើយឈប់និយាយប៉ូរប៉ាច់នឹងនារីម្នាក់នៅក្បែរផ្សារត្រី ។

Websites: WatKhemaraRatanaram.org or WatKhmers.org



## បាត - បាត្រ - បាទ

បាត =( ផ្នែកខាងក្រោមនៃដំពៅផ្ទៃដៃ - ជើង ) បាតដៃ

បាតបឹង - បាតខ្ទះ - ឫសដូងបាត - បិណ្ឌបាត...

បាត្រ =(ភាជនៈ) = បាត្រលោក - បាត្រដែក - ស្លោកបាត្រ

បាទ (ជើង) - ព្រះបាទ - ប្រាក់បាទ - ក្រាបទៀបព្រះ

បាទា - សត្វចតុប្បាទ...

ប ជើង ដ មានពាក្យតែ ៤ ម៉ាត់ = ប្ដី - ប្ដឹង - ប្ដូរ - ប្ដេជ្ញា ។

ម្ដាយខ្ញុំបាទគាត់បានធ្វើប្រាក់ទៅទិញបាត្រមួយ នៅស្រុកសៀមថ្លៃម្ភៃបាទ ពងឈើ បាតរាបស្មើដូចជាបាតខ្ទះ ទុកប្រគេនលោកបងខ្ញុំដាក់បង្ហាន់បិណ្ឌបាត ។

## បំរាស - បំរាស់ - បំរះ

បំរាស ឬ បម្រាស = កិ. ធ្វើឲ្យប្រាស ឲ្យឃ្លាតចេញ

ប្រាសព្រាត់....

Websites: WatKhemaraRatanaram.org or WatKhmers.org


បំរាស់ ឬ បម្រាស់ ពាក្យសម្រាប់និយាយផ្ទុំនឹងពាក្យបំរើ
បំរើបំរាស់ គឺទទួលភារៈតាមកិច្ចដែលគេប្រើប្រាស់....។

បំរះ ឬ បម្រះ ឬ បង្រិះ = បំរះនទៀល – ប្រះប្រាណទៀល
ទៅមកទៀយ ៗ ។

កុមារីនេះខំបំរើបំរាស់មាតាណាស់ លុះដល់មាតាប្រាសព្រាត់ពោល
ទៅក៏យំប្រះប្រាណទៀល សោកស្តាយមាតាឥតមានល្ហៃឡើយ

| បះ-ប៉ះ-បាស |
|---|

បះ = ការបះបុងមាន់ – បះបោរនឹងទទឹង – នាំគ្នាបះឈប់ធ្វើការ

ប៉ះ – ប៉ះទង្គិច – ប៉ះសំពត់ក្បាប់ – ទមគោប៉ះគ្នា – ប៉ះមុខគ្នា – ប៉ះ
ពារ – ប៉ះពាល់...

បាស =(អម្បោះបង់សំពត់ស្អប)- ខ្សែបាស - បន្ទុំស្ទឹកបាស
«បាស់ សរសេរដូចនេះគ្មានទេ» ។

ថ្ងៃមួយ នៅស្រុកមាខ្ញុំ មានមនុស្សបះបោរផ្តើលនោឡោរត់ប៉ះ
ទង្គិចគ្នា ខ្លះភ័យរត់បុះទឹក ខ្លះរត់ទៅពួនសម្ងំកង់ក្រៃបន្ទុំបាស ។

Websites: WatKhemaraRatanaram.org or WatKhmers.org



## បង្កាន់ - ប្រកាន់

បង្កាន់ដៃ = ន. បង្កាន់ដៃស្ពាន - សំបុត្របង្កាន់ដៃ...

ប្រកាន់ = កិ. ប្រកាន់ទោស - ប្រកាន់ពូជបក្ខ... ។

កាលពីថ្ងៃមុន ខ្ញុំបាទបានបង់ពន្ធអាកររូបហើយ មានទាំងបង្កាន់ដៃសំគាល់ទៀតផង ឥឡូវនេះមានគេមកប្រកាន់ថាខ្ញុំបាទពុំទាន់បង់ពន្ធនោះទេ ។

## បញ្ញត្ត - ប្រព្រឹត្ត - បញ្ញត្តិ - ប្រព្រឹត្តិ

បញ្ញត្ត - ប្រព្រឹត្ត = (កិ. គុ.) រាជការបញ្ញត្ត - ប្រព្រឹត្តទុច្ចរិត - មានច្បាប់បញ្ញត្ត - សិស្សប្រព្រឹត្តសុចរិតត្រឹមត្រូវ...

បញ្ញត្តិ - ប្រព្រឹត្តិ = (ន.) មានបញ្ញត្តិ - ការប្រព្រឹត្តិ - ខុសនឹងបញ្ញត្តិ - សេចក្តីប្រព្រឹត្តិ - ត្រូវធ្វើតាមបញ្ញត្តិ...

សិស្សល្អ ប្រព្រឹត្តសុចរិតតាមបញ្ញត្តិ ។ មានព្រះរាជប្រកាសបញ្ញត្តដល់មនុស្សទុច្ចរិតឲ្យខំប្រព្រឹត្តត្រឹមត្រូវ ។ ការប្រព្រឹត្តិល្អឥតមានខុសនឹងបញ្ញត្តិ នាំឲ្យបានសុខគ្រប់ប្រការ ។

Websites: WatKhemaraRatanaram.org or WatKhmers.org



" ចូរចំណាំពាក្យពីរម៉ាត់ខាងលើនេះ បើជាកិរិយាឬគុណនាមត្រូវសរសេរ "ត្ត" បញ្ញត្ត, ប្រព្រឹត្ត បើជានាមវិញ ត្រូវសរសេរ "ត្តិ" បញ្ញត្តិ ប្រព្រឹត្តិ

## ប្រណិប័តន៍ – បដិបត្តិ ឬ ប្រតិបត្តិ

ប្រណិប័តន៍ = ន. (ការសំដែងសេចក្ដីគោរព – ការគំនាប់ ឬសំពះ) សូមក្រាបប្រណិប័តន៍ ចូលមកលោក...

បដិបត្តិ ឬ ប្រតិបត្តិ = (ម.សំ.) (ការប្រព្រឹត្ត – កាន់ – ធ្វើតាម) សេចក្ដីបដិបត្តិ – ត្រូវប្រតិបត្តិតាមច្បាប់ ។

អ្នកត្រូវប្រណិប័តន៍ចាស់ព្រឹទ្ធាចារ្យវេលាអ្នកជួបប្រទះតាមផ្លូវ ។ នៅសាលារៀនត្រូវគោរពប្រតិបត្តិគ្រូកុំបីឲ្យឃ្លង ។ បើចេះធម៌ចេះច្បាប់ត្រូវតែបដិបត្តិតាមទើបបានប្រសើរ ។

## ប្រឹក្សា–ព្រឹក–ព្រឹក្សា

ប្រឹក្សា = ការពិចារណា – ពិគ្រោះគ្នា – ប្រឹក្សាគ្នា ...

ព្រឹក = ព្រឹកព្រហាម – ព្រឹកស្អែក – ព្រឹកល្ងាច ...

Websites: WatKhemaraRatanaram.org or WatKhmers.org



ព្រឹក្សា = ឈើទាំងពួង ព្រៃព្រឹក្ស-ពោធិព្រឹក្ស... ។

ព្រឹកស្អែកនេះ រដ្ឋាភិបាលនឹងប្រឹក្សាសម្រេចអំពីផលដែលបានមក ព្រឹក្សាជាតិទាំងឡាយក្នុងប្រទេសកម្ពុជា ដើម្បីនឹងកម្រិតពន្ធដារតាម …ញាតិ ។

## ប្រៀប - ព្រាប - ព្រៀប

ប្រៀប = ប្រៀបធៀបប្រដូច-ប្រៀបផ្ទឹម.និយាយប្រៀបប្រាយ...

ព្រាប = ព្រាបយំថ្ងូរ-ព្រាបសប្រផេះ...

ព្រៀប = ទឹកជន់ព្រៀបច្រាំង-ពេញព្រៀបមាត់ឆ្នាំង... ។

លុះដល់ខែវស្សា ស្រះវត្តយើងមានទឹកពេញព្រៀបហូរហៀរ …ប្រៀបដូចជាទឹកទន្លេឡើងលិច មានព្រាបឈ្មោលញីហើរព្រាតព្រោង …រកស៊ីនៅលើមាត់ស្រះឥតមានស្រាកស្រាន្ត ។

## ប្រុស - ប្រុះ - ប្រេះ - ប្រោស - ប្រោះ

ប្រុស = (បុរស) កូនប្រុសស្រី-ក្មួយប្រុស...

Websites: WatKhemaraRatanaram.org or WatKhmers.org



ប្រុះ = ភ្លឺប្រុះព្រោងព្រាយ ភ្លឺប្រុះឆ្ពុះឡើង...

ប្រេះ = កើតទុក្ខស្ទើរប្រេះទ្រូងស្លាប់ – ផ្លែឈើទុំប្រេះ...

ប្រោស = ប្រោសសត្វ – ពានប្រោស – សូមប្រោសប្រណី យកឆ្មាទៅប្រោស...

ប្រោះ = ប្រោះទឹក, ប្រោះត្រី, មើមប្រោះ, ប្រោះឲ្យមានជីវិត..

តាំងតែពីកូនប្រុសនោះធំឡើងកាលណា ម្តាយកើតទុក្ខស្ទើរប្រេះទ្រូង វេលាយប់វាទៅលួចត្រីដែលគេប្រោះទុកបរិភោគ ជួនកាលវាចា ឆ្មាយកទៅប្រោសពេលឥតមានមេត្តា ។

## ប្រេង – ព្រេង

ប្រេង = ន. ប្រេងកាត – ប្រេងដូង – ប្រេងល្ង – លាបប្រេង

ព្រេង = គុ. បុរាណ – គូព្រេង – ទ្រព្យព្រេង – ពាក្យព្រេង – ព្រេងព្រឹទ្ធ.... ។

នៅស្រុកស្រែចំការ គេអុជប្រេងកាតឬខ្លាញ់ត្រី ក៏ព្រេងតែ

នៅទីក្រុងធំៗ មានភ្លើងអគ្គិសនី ភ្លឺប្រុះឆ្ពុះគ្រប់គេហដ្ឋានទាំងអស់

Websites: WatKhemaraRatanaram.org or WatKhmers.org



## ផ្សា - ផ្សារ

ផ្សា = ផ្សាខ្ទាប - ផ្សះផ្សាគ្នា - ថ្នាំដំបៅនេះផ្សា....

ផ្សារ = ផ្សារផ្សា - ទៅលេងផ្សារ - ផ្សារនេះស្ដុកស្ដម្ភ - ផ្សារភ្ជាប់ឲ្យជិត - ផ្សារបង្កៀងនឹងទឹកបន្សារ... ។

កាលពីថ្ងៃសៅរ៍មុន មេឃុំបានផ្សះផ្សាអ្នកលក់បន្លែនៅផ្សារ អំពី ឈ្លោះវាយគ្នាមានរបួសឈឺផ្សា ជាប់ទាំងជាងផ្សារម្នាក់ធ្វើជាសាក្សី ទៀតផង ។

## ព - ពរ - ពារ - ពៀរ

ព = ស្រីពកូន - ពពោះ - ពគំនរទុក...

ពរ = ឲ្យពរ - ទទួលពរសព្ទសាធុការ - ពរជ័យ...

ពារ = ការពារ - ពាររបង - ដើរពានពារលើគល់ឈើ...

ពៀរ = ចងពៀរ - មានពៀរវេរានឹងគ្នា - ពៀរពាំនៀរ... ។

បងខ្ញុំបានប្រទះនឹងស្រីម្នាក់ខ្វាក់ភ្នែកទាំងពីរ ពកូនដើរសូមទានគេ

Websites: WatKhemaraRatanaram.org or WatKhmers.org



ជួនកាលដើរពារលើបន្ទា ជួនណាប៉ះនឹងដង្គត់ឈើ បើគេដាក់ទានអ៊ុំឡើង គាត់លើកដៃសំពះជូនពរសព្វសាធុការគេ សេចក្ដីវេទនានេះមកពីមានពៀរវេរតាមមកផ្ដល់ ពាំនៀរទាំងនោះមិនដែលសាបសូន្យទេ ។

## ពិ _ ពី _ ពីរ

ត្រូវចំណាំពាក្យពីរម៉ាត់ «ពិនឹងពី» ដែលអ្នកសរសេរច្រើនច្រឡំជាញឹកញយ ហើយគិតស្មានថាឥតខុសទៀតផង ។ ពាក្យដែលមាន «ពី» នៅខាងមុខ នោះមានចំនួនតិចជាង «ពិ» នៅខាងមុខ ដូចមានខាងក្រោមនេះ៖

ពិ = ពិការ, ពិគ្រោះ, ពិឃាដ, ពិនិត្យពិច័យ, ពិចារណា ពិចិត្រ, ពិជ័យ, ពិដោរក្ខន, ពិតាន, ពិទូរ្យ, ពិន័យ, ពិបាក ពិពេធ, ពិសាខបូជា, ពិសេស, ពិសោធន៍ ។ ល ។

ពី = ន. កា. និ: (អំពី – ខាង – ឯ) មកពីណា, រូបពីដៃ, សំដីចេញពីមាត់, ពីមុខ, ពីក្រោយ , ពីព្រោះ, ពីរេះ, ពីសីឬពិសី ពីសាឬពិសា, ពាក្យដែលមាន «ពី» នៅពីមុខមានតែប៉ុណ្ណឹង

ពីរ = ( ចំនួនមួយនឹងមួយគួបគ្នាត្រូវជាពីរ ) ពីរ បី... ។

Websites: WatKhemaraRatanaram.org or WatKhmers.org



កាលពីថ្ងៃមុនខ្ញុំបានមកពីគ្រោះទឹងលោក សូមឱ្យលោកពិនិត្យរឿង
ស្រពិកាំរ អំពីហេតុដែលគេពិន័យឥតមានពិភាក្សាឱ្យឃើញខុសត្រូវ
ភះ ។

## ពេចន៍–ពេជ្រ–ពេជ្ឈ

ពេចន៍ = ន. (ពាក្យសំដី) ពាក្យពេចន៍ – អ្នកបេះពាក្យពេចន៍

ពេជ្រ = ត្បូងពេជ្រ – ចិញ្ចៀនពេជ្រ – ពេជ្របុ...

ពេជ្ឈ = ពេជ្ឈឃាដឬឃាត (អ្នកពិឃាតមនុស្សទោស)... ។

អ្នកបំនួញក្លឹងម្នាក់រកស៊ីលក់ត្បូងពេជ្រគ្រប់យ៉ាង បេះពាក្យពេចន៍
ឱ្យចង់ស្ដាប់ ចាំរឿងព្រេងជាច្រើន គាត់និទានថា មានព្រះមហា
ក្សត្រិយ៍មួយព្រះអង្គទ្រង់ត្រាស់បង្គាប់ពេជ្ឈឃាតឱ្យយកមនុស្សក្បត់ម្នាក់
ពិឃាតឥតមានជំនុំជំរះ ។

## ពត់–ពុត–ពុទ្ធ–ពុធ

ពត់ = ពត់ដម្រង់ ពត់ចិត្ត, ពត់ព្រួញ....

Websites: WatKhemaraRatanaram.org or WatKhmers.org



ពុត = ពុតត្បុត, មានពុត, ដេញពុត, សម្លាប់ពុត

ពុទ្ធ = ព្រះពុទ្ធរូប, ព្រះពុទ្ធ, ធម៌, សង្ឃ, ពុទ្ធដីកា

ពុធ = ថ្ងៃពុធ ផ្កាយពុធ... ។

ពីថ្ងៃពុធ មានកុមារម្នាក់ពុតធ្វើជាឈឺ គេចវេះមិនទៅសាលារៀន បង់តាមលោកទៅលេងផ្សារទិញស្បង់ចីពរនិងព្រះពុទ្ធរូប កិរិយាក្មេងបែបនេះពិបាកពត់ដម្រង់ណាស់ ។

## ពស់–ពោះ–ពោធិ៍–ពោរ

ពស់ = ពស់វែក, ពស់ព្រលឹត, ពស់ក្រាយ...

ពោះ = ឈើពោះ, មានពោះពុង, ពោះម៉ាយ...

ពោធិ៍ = ដើមពោធិ៍, ពោធិព្រឹក្ស, ព្រះពោធិសត្វ, ខេត្តពោធិ៍សាត់

ពោរ = ពោរពេញ, ពុះពោរ, ពេងពុម្ពមានសៀវភៅពោរពាស

លោកបានបញ្ជាពេងពុម្ពឈើពោះ ពីព្រោះលោកពិសាគ្រប់ពោធិ៍សាត់ដែលគេលក់ពោរពាសនៅតាមផ្លូវ ឥឡូវនេះបានថ្នាំស្រាប់ពស់វែកពេកពោះនោះគ្រាន់បើហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org


## ព្រ័ត្រ - ព្រាត់

ព្រ័ត្រ= ព្រ័ត្រក្របី, វេញព្រ័ត្រ, អុំទូកកាត់ព្រ័ត្រ

ព្រាត់= ព្រាត់ប្រាសគ្នា, ព្រាត់មិត្រសំឡាញ់... ។

ក្នុងឱកាសចូលឆ្នាំខ្មែរមានល្បែងច្រើនយ៉ាង ខ្លះលេងឈូង ខ្លះទាញព្រ័ត្រ ខ្លះបរគោក្របីសេះ អ្នកណាមានទុក្ខទោសព្រាត់ប្រាសនិរាស យ៉ាងណាក៏បានល្ហែទីងគេដែរ ។

## ព្រុស - ព្រូស - ព្រួស - ព្រោះ

ព្រុស= កិ. ឆ្កែព្រុស, ឆ្កែព្រុសមិនដែលខាំ ។

ព្រូស= ន. ដើមព្រូស, ព្រីងព្រូស ។ ព្រូស. ។. (ស្ងួតព្រៀ ដោយផ្លួល) ផ្លួលព្រូស

ព្រួស= កិ. ព្រួសទឹក ស្ដោះព្រួស ។

ព្រោះ= កិ. ព្រោះស្រូវ, ព្រោះថ្នាំ ។ ព្រោះ អា. និ. (ហេតុផ្សិត) ព្រោះឈឺ, ព្រោះខ្ជិល...

Websites: WatKhemaraRatanaram.org or WatKhmers.org

ផ្លែតាព្រហ្មពាំព្រហ្ម ឆ្មាមួយអង្គុយនៅប្រគាបដើមព្រហ្ម ឆ្មាភ័យព្រ
ស្រែកព្រហ្មទឹកមាត់ព្រោះខ្លាចផ្លែខាំ ៗ

---

## ពាក្យទំនឹមទំនៀមបុរាណ

- ស្តុកស្លាប់ វៀចវរមានភ័ព្វ អាយុយឺនយូរ
- សេកគាប់ឆាប់កគ្ងរ
- គ្របីស្លូនគែក មនុស្សស្រលៀនភ្លូក ក្រពើកំបុតកន្ទុយ
- អន្ទង់វែង រកឆ្នាំងវែង
- បង់ពោយឲ្យមើលប្រាណ ដាំដើនក្រានឲ្យប្រមាណឆ្នាំង
- ចំពក់ពាំទៅ ទើបព្នៅពាំមក
- លួចគេធ្លាប់ដៃ ដេកថ្ងៃធ្លាប់ភ្នែក
- ស្រឡាញ់កុំទៅញឹក បើរញុកសឹមទៅម្តង ៗ
- កាលឈឺយកដំរីទៅបន់ លុះជម្ងឺស្រន់ពងមាន់មួយស្តាយ
- មានសំពម ទើបផ្លែកផ្ទុះ
- ផ្លែព្រហ្មមិនដែលខាំ
- ដំបៅមិនឈឺ យកឈើចាក់
- ម្នៅ ៗ យកដ័រព្នៅមកគ្បៀតគ្បៀក

Websites: WatKhemaraRatanaram.org or WatKhmers.org



– សូវស្លាប់បាឡៀតធំមេ សូវលិចទូកកណ្ដាលទន្លេ កុំឲ្យតែភ្លើងឆេះផ្ទះ

– ទៅឥតគេរក មកឥតគេហៅ

– ទឹកត្រជាក់ត្រីកុម

– កំភ្លាញស្លាប់ពីព្រោះមាត់

– អឹមអៀមស្ងៀមជាជាងស្រដី ស៊ីបេកខ្ទីជាជាងនៅមាត់ទទេ

– កុំទុកចិត្តមេឃ កុំទុកចិត្តផ្កាយ កុំទុកចិត្តស្រីថាគ្មានសហាយ
កុំទុកចិត្តម្ដាយថាគ្មានបំណុល

– ទាហានស្បែកជាប ខ្លាចស្បែកស្វិត

## ភក្តិ–ភក្ត្រ–ភប់–ភព–ភ្លក្ស–ភ្លុក

ភក្តិ ឬ ភ័ក្តិ= ញាតិភ័ក្តិ–មិត្រភក្តិ–ស្វាមីភក្តិ–ជំទប់ភក្តី

ភក្ត្រ ឬ ភក្ត្រ= ព្រះភ័ក្ត្រ–ស្រពព្រះភក្ត្រ (លុបលាងមុខ)...

ភប់= កិ. ជួប–ប្រទះ–គប់ប្រសព្វ ៗ

ភព= (ម.ថ.កប់) សេចក្ដីបំរើន–ដំណើរកើត–ពិភពលោក ៗ

ភ្លក្ស ឬ ភ្លក់= ភ្លក្សម្ហូ–ភ្លក់ឲ្យដឹងសាបប្រៃ . . . .

ភ្លុក= ភ្លុកដំរី–បូជាសពមានភ្លុក ៤ នាក់–ភ្លុកខ្មោច . . . ៗ

Websites: WatKhemaraRatanaram.org or WatKhmers.org


កូនកុដិលោកគ្រូបៅអធិការមានកុកដីរមួយគូ ដំកល់នៅចំព្រះភក្ត្រ ព្រះមានលោកពិភ័ក្តិរក្សាយប់ថ្ងៃដោយថ្នាក់ថ្នម ។ កូនពិភពលោកនេះត្រូវកប់ប្រសព្វនឹងអ្នកប្រាជ្ញទើបមានភ័ព្វល្អ ។

ព្ទ និង ភ្ទ

ចូរចំណាំអក្សរពីរតួ « ព្ទ និង ភ្ទ » ដែលគេច្រើនច្រឡំរបៀបផ្ញើជើង ទ្ទ និង យ្យ ។

ជើងទ្ទត្រូវនៅក្រោមភ–ភ្ទ ។

ជើងយ្យត្រូវនៅក្រោមព–ព្យ ។

ភ្ទ= ភ្ទរភ្ទាប់ភ្ទុត-ភ្ទេញសំពត់-ភ្ទុំភ្ទុរ-ភ្ទួរស្រែចំការ-ផ្ញាំងភ្ទុល

ព្យ= ព្យាយាម - ព្យាបាទ - ព្យាបាល - មួយព្យាម - ខ្យល់ព្យុះ - ព្យួរទោសប៉ែខ.... ។

លុះដល់ខែភ្ជុំបិណ្ឌ អ្នកស្រុកទៅភ្ជុំគ្នានៅវត្ត ដាក់បិណ្ឌរាល់ព្រឹកខ្ទះព្យាយាមណាស់នៅសំណាក់កូនវត្ត មានចង្កៀងអុជព្យួរភ្លឺព្រោងព្រាតវេលាយប់ ។

Websites: WatKhemaraRatanaram.org or WatKhmers.org


## ម៉ត្ត ឬ ម៉ដ្ឋ  ម៉ត់ ឬ ហ្មត់

ម៉ត្ត ឬ ម៉ដ្ឋ = (ម.ថ.ម៉ត់) (ដែលមានសាច់ល្អិត-សុទ្ធដិត)

. សំពត់សាច់ម៉ត្ត . មេឃម៉ដ្ឋខៃ...

ម៉ត់ ឬ ហ្មត់ = (អស់ល្អិត- មិនមាន- មិនសល់) -ស៊ីហ្មត់-

ចោរលួចហ្មត់...

ហ្មត់ចត់= (ស្អាត - បរិសុទ្ធ) - ចិត្តហ្មត់ចត់ - ធ្វើការហ្មត់ចត់

(កុំសរសេរ ម៉ត់ចត់-ម៉ត់ម៉ង់ យ៉ាងនេះពុំស្រួលប្រើ) ។

ចិនម៉ៅទៅផ្សារដើររកទិញសំពត់សាច់ម៉ដ្ឋល្អ គាត់រើសហ្មត់ចត់ណាស់បានប្រាំក៏ លុះយកទៅផ្ទះមានគាចោរលួចហ្មត់ក្នុងយប់នោះទៅ ។

## មាឌ ឬ មាត្រ . ម្រ័ក្សណ៍ . ម្រាក់

មាឌ ឬ មាត្រ= ម.ថ. មាត (រាស់ - ថ្វីង - រូបរាង - ទម្ងន់ ទំហំ)-មាឌធូក-មាត្រកប៉ាល់-មាត្រប៉ុនគ្នា,

ម្រ័ក្សណ៍= ម.ថ. ម្រាក់-ន. លាបម្រ័ក្សណ៍ ម្រ័ក្សណ៍ខ្មែរ-

Websites: WatKhemaraRatanaram.org or WatKhmers.org



ស្រាក់= ន. (ក្មេងស្រីទើបនឹងស្រី) –ក្មេងទើបនឹងស្រាក់... ។

ក្មេងទើបនឹងស្រាក់មាឌប៉ុនគ្នា ប៉ុន្តែ ក្មេងប្រុសជាតិជាក្មេង បានជាគាត់ខ្ទេ ររលោងដូចម្រ័ក្សណ៍ ។

## យ៉ង់-យ៉ន្ត-យ័ន្ត

យ៉ង់= យប់យន់-យន់ត្របកភ្នែក–យន់កម្លាំង...

យ៉ន្ត ឬ យ៉ន្ត្រ= ម.ថ.យន់ – យន្តដេរ – យន្តហោះ–រថយន្ត ...

យ័ន្ត ឬ យ័ន្ត្រ= ម.ថ.យ័ន – គូរយ័ន្ត – បញ្ចុះយ័ន្ត–យ័ន្តការពារ

សត្រូវ...

យប់យន់ណាស់ទៅហើយ គេឮសូរយន្តហោះហើរលើអាកាស ខ្ញុំភិតភ័យទាញយកពិតានដែលមានយ័ន្ត មកទទូរគ្របក្បាលការពារ សត្រូវ ។

## យ៉ា-យ៉ារ-យុត្តិ-យុទ្ធ

យ៉ា= យាយី–បីសាចមកយាយី (បៀតបៀន)...

Websites: WatKhemaraRatanaram.org or WatKhmers.org


យារ = ក្បៀនយារ – ស្រែកយារ...

យុត្តិ ឬ យុត្ត = ត្រឹមត្រូវ – យុត្តិធម៌ (សេចក្ដីត្រឹមត្រូវ, ទៀងត្រង់)

យុត្តការណ៍ (ហេតុដំណើរដ៏គួរ) យុត្តកិច្ច

(កិច្ចត្រឹមត្រូវ)....

យុទ្ធ = ចម្បាំង, សង្គ្រាម, តយុទ្ធនឹងគ្នា... ។

ប្រពន្ធបុរសនោះមិនមែនជាស្រីមាយាទេ គ្នាឈឺយូរយារណាស់មក ហើយ គ្រូទាយថាខ្មោចខាងម្ដាយមកយាយី ឥឡូវប្ដីខឹងប្ដឹងលែង ប៉ុន្តែ ចៅក្រមវិនិច្ឆ័យក្ដីនេះដោយយុត្តិធម៌ កាត់សេចក្ដីថាត្រូវជានឹងគ្នាវិញ ។

| រត់ – រថ – រុត |
|---|

រត់ = រត់លឿន – រត់បោលស្រុក រត់ពួន – រត់ទ័ព...

រថ = រទេះរថ រថសេះពីរ – ជិះរថទៅលេងកំសាន្ត

រុត = រុតត្រី – យកអង្រុតទៅរុតត្រី... ។

ពីដើមមានរថសេះមួយ ឬសេះពីរជាច្រើន ឥឡូវនេះគេប្រើរទេះឡានវិញ រត់លឿនជាងរថទាំងអស់ ។ អ្នកស្រែរុតត្រីនឹងអង្រុត បើត្រីបោលក្នុងទឹក គេស្ទុះលោតរត់តាមស្ទាក់ពីមុខពីក្រោយ ទាល់តែរុតបាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org



## រន្ធ – រុធ – រស – រស់

រន្ធ =(ម.ថ.រន្ធ) – រូង – រន្ធកណ្ដុរ – រន្ធបច្រិត

រុធ = ពួកកក់ – ដើមរុន – គន្លុយរុន

រស = (ម.ថ.រស់) – សម្ពស្សប្លែក ៗ ដែលប៉ះពាល់ជិវ្ហាបសាទ ឲ្យដឹង ប្រៃ, ជូរ, ចត់, អាហារមានរសឆ្ងាញ់

រស់ = មានជីវិតនៅ – រស់នៅ បានរស់ពនមានជីវិតតទៅ ៗ ចៅរស់ឃើញរន្ធក្ដាមនៅក្បែរគុម្ពរុន កំលូកដៃចាប់បានក្ដាមមួយ យកទៅដុត អាស្រ័យទាំងរស់មានរសជាតិក្រៃលែង ៗ

## រាក – រាគ – រាង – រៀង

រាក = (គឺលេចដោយពន់ខ្លាំងទប់មិនទាន់) – គ្រុនរាករោម រាកអាចម៍ – ចុះរាក – រាករូស មាន់រាកស៊ុត...

រាគ = ម.ថ.រាគៈ (គឺតម្រេកត្រេកត្រអាលចំពោះកាម) ចិត្តប្រកប ដោយរាគៈ...

រាង = រាងចាល – រាងលែងធ្វើទៀតហើយ – រូបរាង – រាងស្ដើង....

Websites: WatKhemaraRatanaram.org or WatKhmers.org



រៀង = ឈររៀងគ្នា រៀងកប រៀងកាយ លេខរៀង... ។

រូបរាងគាត់ស្គាំងស្គមរៀងកាបដាបមក ដោយរាគៈគ្របសង្កត់ ហើយនឹងពេគពកជានិច្ចទៀតផង ។

## រង់ – រង្គ – រុង

រង់= ការង់ រង់ចាំបន្តិចសិន...

រង្គ=ម.ថ. រង់ (គ្រឿងជ្រលក់ពណ៌លឿង) – ជ័ររង្គ ...

រុង=រុងរឿង – ថ្កុំថ្កើង (កុំសរសេរយ៉ាងនេះរង់រឿង) ថ្កុំថ្កើងឬ ថ្កុំថ្កើន ប្រើបានដូចគ្នា ។

បើជានគន្ទរមកដល់ ឲ្យគាត់រង់ចាំខ្ញុំសិន ខ្ញុំនឹងទៅជាមួយបង្ហាញ ផ្ទះដែលមានរង្គលក់ច្រើន រើសយកតែពណ៌ស្រស់ល្អរុងរឿង ។

## រាជ – រាជ្យ

រាជ= (សរសេរឥតជើង «យ្យ») រាជសម្បត្តិ គឺសម្បត្តិ របស់ព្រះរាជាសំរាប់ព្រះអង្គ ដូចជា រាជទ្រព្យ–រាជនាវា–រាជបុត្រ–រាជទូត–រាជប្រកាស...

Websites: WatKhemaraRatanaram.org or WatKhmers.org



រាជ្យ =សរសេរមានជើង "យ" រាជ្យសម្បត្តិ គឺសម្បត្តិ

សំរាប់រាជ្យឬសំរាប់ផែនដី ពុំមែនសំរាប់ព្រះរាជាទេ ដូចជាព្រះច័ន្ទរាជ្យ - មកុដរាជ្យ - បល្ល័ង្គរាជ្យ - សោយរាជ្យ - ប្រទេសឯករាជ្យ

ព្រះច័ន្ទរាជ្យគេដំកល់ទុកក្នុងព្រះបរមរាជវាំងគឺជាទ្រព្យសំរាប់រាជ្យ ។

«ការចំណាំ៖ បើពាក្យ (រាជ) នៅចុងពាក្យត្រូវសរសេរ រាជ ជើង - យ (រាជ្យ) ដូចជាព្រះច័ន្ទរាជ្យ, មកុដរាជ្យ»

**រាន - រៀន - រាប - រៀប**

រាន= រានហាល - រានមាន់ - លក់រាន - រានស្រែចំការ

រានភូមិ - មនុស្សរានចំណី - រុករានទន្ទ្រាន...

រៀន= រៀនធ្វើការ - រៀនសូត្រ - រៀនចំណេះវិជ្ជា

រាប= ដីរាប - គោរាប - ចុះពាក្យរាបទាប - រាបស្មើ - រាបសា

រៀប= ទៀប - ហៀប - រៀបស្លាប់ - រៀបទឹកណាគ្នា - រៀបចំ

រៀបខ្លួនប្រាណ...។

សិស្សម្នាក់ចុះពាក្យរាបទាប អង្គុយទន្ទេញមេរៀន នៅរានហាលមុខផ្ទះ ដែលមានជើងផ្ការៀបជាក់ជាជួរ ។

Websites: WatKhemaraRatanaram.org or WatKhemers.org



## ភារ - ភៀរ

ភារ= ការចាប់ត្រី ការគេឲ្យឃើញ - ខ្ញាញ់ភារ - បបរភារ - ភារបាន ។

ភៀរ= ពងភៀរ, រំពាត់ភៀរ, តួបភៀរ

មានគាពោរម្នាក់ពងភៀរខ្ពស់ ចូលទៅផែបក្បែរផ្ទះបាយ គេហើយលូកដៃតាមបន្ទោះជញ្ជាំងភារគេរបស់ទ្រព្យ ក៏ប្រទះបាន បានមួយភារយ៉ាងថ្មី ។

## លក្ខ - លក្ខណ៍ ល័ក្ត - លាក់

លក្ខ ឬ លក្ស=ម.ថ.ល័ក ន. កំរិត សេចក្ដីកំណត់ ទំមានលក្ខ ខណ្ឌ - សំដីមានលក្សខណ្ឌ ។

លក្ខណ៍ ឬ លក្សណ៍= ន. ស្រីមានលក្ខណ៍ - ខាតលក្ខណ៍ - លក្ខណៈបរិបូណ៌

ល័ក្ត ឬ ល័ខ= ន. ល័ខជុំគន្ធ - ល័ខខៀវ - ល័ខខ្មៅ

លាក់=កិ. លាក់របស់, លាក់ពុត, កាប់លាក់ឈើ... ។

Websites: WatKhemaraRatanaram.org or WatKhmers.org



មនុស្សនេះខាតលក្ខណ៍ គាត់សក់លាក់ជើងកញ្ចើ និយាយប៉ប៉ាច់ប៉ប៉ោចឥតមានលក្ខខណ្ឌ ហើយស្លៀកខោជ្រលក់ល័ខបៃតងខុសពីគេទៀតផង ។

| លក់ - លុក - លង់ - លុង |
|---|

លក់=លក់ទំនិញ - លក់ថ្លៃ - ដេកលក់ - លក់លន់

លុក=លុកលុយ - លុកទ័ព - លុកព្រៃ - ចូលលុកក្នុងផ្ទះ

លង់=ជ្រុលហួសស៊ុន - លង់គំនិត - លង់ទឹក - យូរលង់

លុង=ជីកជាប់ជារលុង - រូង - រូងលុងដី - លុងឈើ - ជីកលុង ។

មេឃុំពិន័យលក់ម្ចាស់សេះដែលធ្វេសប្រហែស លែងសត្វពាហនៈនេះឱ្យលុកលុយស៊ីដំណាំគេ ប៉ុន្តែម្ចាស់អង្វរថា ខ្ញុំបាទបានជាលង់គំនិតគិតតែលុងឈើធ្វើទូកជបមួនគេយកបុណ្យ ។

| រលា - លលា - លលាដ៍ |
|---|

រលា=កិ. ឬ គុ. (រសាយរមួរ រសាយបំណង) ខ្សែរលា

របុំអំពោះរលា....

Websites: WatKhemaraRatanaram.org or WatKhmers.org



លលា=(ម.ថ. លៈលា) គុ. លលាទឹកមាត់, (ទ្រុតទឹកមាត់, ពាក្យពាក្យ) អាលលាតែ (និយាយក្លាយជាលេលាក៏មាន)

លលាដ៍= (ម.ថ.លៈលា ) ន. (ឆ្អឹងក្បាល) លលាដ៍ក្បាល លលាដ៍ដូង ។

អាលលាតែម្នាក់ កាន់លលាដ៍ដូងនៅដៃ ដើរទៅឈរក្បែរស្រីម្នាក់កំពុងត្បាញសំពត់ ហើយយកលលាដ៍ដូងបោលទៅលើក្តារមូរដាប់រលាត់ពោះអស់ ។

## លប់ - លុប - លស់ - ល្អស - លោះ

លប់= ន. លប់លលក. លប់ទទា, ក្រួចដាប់លប់...

លុប = កិ. លុបអក្សរ, លុបមុខ, លុបលាង, សំដីលុបលើ.....

លស់=កិ. គ្រុនលស់, ដើរលស់ជំហាន, លស់លាគ្រាប្រណី

ល្អស=កិ. ន. ល្អសមែកឈើ, ល្អសអំពៅ ល្អសសំណ រល្អសបាយ, រល្អសផ្អូន...

លោះ= កិ. លោះរបស់បញ្ចាំ លោះកែកាំភ្លើង – លោះស្នា ។

ស្រានវៃព្រះគ្រោកពីព្រលឹមលុបមុខយ៉ាងរហ័ស រួចវាញយកលប់

Websites: WatKhemaraRatanaram.org or WatKhmers.org



ទៅដាក់លលកព្រាប គាត់យកលួសចងលប់ភ្ជាប់នឹងកូនរលួសមួយដើ
តួប ព្រាននេះចិត្តអាក្រក់ណាស់ឥតមានលស់លាត្រាប្រណីអ្នកណា
ឡើយ អំពើអាក្រក់នេះហើយ បានជាព្រានក្រលំបាកលក់កូនឲ្យនៅ
គេរកប្រាក់លោះកូនពុំបាន ។

**លាង – លៀង – លាប – លាភ – លៀប**

លាង = កិ. លាងដៃ – លាងចិត្ត – លាងបាប – លាងពៀរ

លៀង = កិ. លៀងជីវិត, លៀងភ្ញៀវ, ស៊ីលៀង, លៀងលោម
លៀងអារក្ស

លាប = កិ. លាបប្រេងម្សៅ – យកឈ្មោះគេមកលាប

លាភ = ន. មានលាភ – កើតលាភ

លៀប = ន. ឈើពួកជ្រៃ ដើមលៀប ត្រួយលៀបប្រើជាអន្លក់ ។

មានមួយយប់នោះគេបានអញ្ជើញមន្ត្រីម្នាក់នឹងភរិយាទៅជប់លៀង ប្ដីនឹងប្រពន្ធក៏មុជទឹកដុសលាងខ្លួនប្រាណ រួចស្លៀកពាក់សិតសក់លាបប្រេងម្សៅផូរផង់ គិតថាយប់នេះលាភយើងដល់ហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org



## លាន – លៀន – លិប – លេប

លាន=ន. លានបោកស្រូវ, លានចេតិយ, មុខព្រះលាន

លៀន=កិ. លៀនអណ្តាត – ក្អែកលៀនត្តែ.....

លិប=កិ.ន. លិបចុះបាត់ទៅ – ទូកលិប – ព្រះអាទិត្យលិប –

លិបកញ្ឆន់លន់កញ្ឆើ – ទិសខាងលិប (ឡិប)

លេប=ចេញពីកំបាំង – កិ. លេចសំដី – លេចដំណឹង – លេចវាល

ចូលព្រៃ – គុ. ភ្អមលេច – ផ្ទះលេច – ន. កើតដំបៅលេច ៗ

បៅលឹមកើតដំបៅលេចលៀនត្តែ ដើរទៅឆ្ងាយពុំបាន អង្គុយ

នៅលានស្រូវផុតកាំ ទាល់តែថ្ងៃលិចទើបដះក្របីទៅផ្ទះ ៗ

## វដ្ដ – វត្ត – វត្ស្រ – វ័ធ – វាត់

វដ្ដ=ម.ថ. វដ្ដៈ ដែលវិល – ដំណើរវិលកើតស្លាប់ – វដ្ដសង្សារ

(ដំណើរវិលកើតស្លាប់) វដ្ដទុក្ខ

វត្ត= វត្តលោក – សាលាវត្ត – វត្តបដិបត្តិ

Websites: WatKhemaraRatanaram.org or WatKhmers.org



វត្សរ៍ ឬ វត្ស =បៀវត្សរ៍ (ប្រាក់ខែឬប្រាក់ឆ្នាំ) សតវត្សរ៍ (ឆ្នាំមួយរយឬមួយខួបរយឆ្នាំ...)

វធ =គ្រប់វធគោញាយពោះស្លាប់.... ។

វ៉ាត់ =វ៉ាត់សន្ទូច-វ៉ាយវ៉ាត់នឹងរំពាត់ ។

បើអ្នកបានធ្វើនាម៉ឺនមានបៀវត្ស ត្រូវតែអ្នកទៅវត្តប្រឹងធ្វើបុណ្យទាន ដើម្បីបាកលះបង់វដ្តសង្សារ កុំធ្វើបាបគេ ជេរពោលវ៉ាយវ៉ាត់ ដោយអំណាចនៃបុណ្យសក្តិ ក្រែងមានពៀរដូចមន្ត្រីខ្លះស្លាប់វេទនាទឹងលង់ទឹក នឹងគ្រប់វធក៏មានដែរ ។

| វ៉ា – វ៉ារ – វៀរ – វ៉ាង – វៀង |
|---|

វ៉ា =កូនគោវ៉ាស្រែករកមេវ៉ា–វ៉ាវល់មកពុំបាន

វ៉ារ =កូនបេះវ៉ារ–ត្រឡាចវ៉ារទៅល្ពៅវ៉ារមក

វៀរ =វៀរបាកទុច្ចរិត–វៀរវែត–វៀរលែង

វ៉ាង =ផ្លូវវ៉ាង គំនិតវ៉ាង–សំដីវ៉ាងវៃ

វៀង =(រាជធានី–ក្រុង–វាំង)–វៀងចន្ទន៍ (ក្រុងចន្ទន៍)–វៀងជ័យ (ក្រុងឬវាំងមានជ័យ)

Websites: WatKhemaraRatanaram.org or WatKhmers.org



កូនក៏ទើបតែនឹងចេះវារ ហើយក៏ជាមនុស្សមានប្រាជ្ញាក៏នៅណាស់ ក៏ធ្វើជំនួញនៅវៀងចន្ទន៍ ក៏វៀរចាកទុច្ចរិតទាំងអស់ ពិតមែនតែវ័យនៅក្មេងនៅឡើយ ។

## វាត-វាទ-វិហា-វិហារ

វាត= កិ. វាតទី, វាតមុខ, វាតដារ, វាតទូក ន. វាតរោគ (ជម្ងឺខ្យល់)

វាទ= ន. កើតវិវាទនឹងគ្នា (កើតហេតុនឹងគ្នា)

វិហា= ន. (អាកាស - ឋានសួគ៌) ហោះហើរលើវិហា (អាកាស)...

វិហារ= ន. (ការនៅ.អាស្រ័យ) សង់វិហារ បុណ្យឆ្លងវិហារ ។ ជាទីវិហារ វាតអំណាចត្រួតត្រាលើជនឯទៀត ឈ្លោះដេរគ្នា ឥឡូវកើតវិវាទនឹងគ្នា ដល់ទៅតុលាការជំនុំជំរះ ។

## ស-សរ

ស= គុ. សំពត់សក្បូស-សត្រសុស

Websites: WatKhemaraRatanaram.org or WatKhmers.org



ស= កិ. សត្រី - សរគឲ្យឃើញ សសេចក្ដី - សហេតុ - សកេរ្តិ៍ សគល់ "ត្រកូលសជាតិ មារយាទសព្វជ"

សរ= ន. ព្រួញ, កាំ, ស្ដេចផ្ទៃនសរ, កូនសរ, សរដៃ

សរ= កិ. រព្យកទឹកឃើញ, សរជាតិ, (ជីនជាតិ) សរញ្ញាណបត្តសរសេន់, សរសើរមារយាទ, សរសេរអក្សរ សរសៃសូត្រ, សសរផ្ទះ, ដើរសសៀរតាមជញ្ជាំង ។

អ្នកនេសាទត្រី យកស្នួយមានមុខស្រួចសដូចសំឡី ទៅសត្រីក្នឹបឹន ។ យក្ខិនីត្រូវសរក្ស័យជីវិត ហើយសរជាតិថា កាលពីមុនខ្លួនប្រព្រឹត្តអំពើអាក្រក់ បានពិឃាតសត្វជាច្រើន ។

## ស័ក - សក្តិ - សាក់

ស័ក= ន. កាល, សម័យ, ឯកស័ក, ទោស័ក, ឆ្នាំជូត សំរិទ្ធិស័ក, ឆ្លូវឯកស័ក, ខាលទោស័ក

សក្តិ ឬ ស័ក្តិ= ន. មានសក្តិ, ស័ក្តិតូច, សក្តិធំ, ថ្នាំស័ក្តិសិទ្ធិ (ពូកែឆុតឆាប់)

Websites: WatKhemaraRatanaram.org or WatKhmers.org



## សត្ត - សត្វ - សាត់

សត្តឬសត្វ= (ម.ឋ. ស័ត) សត្តឃាត ឬ សត្វឃាត (ការសម្លាប់សត្វ) ផ្សារសត្តឃាត (ផ្សារពិឃាត) សាប់សត្វ-ព្រះពោធិសត្វ... ។

សាត់= (ប៉ើន - ហើរតាមខ្យល់ - អណ្តែតតាមទឹក) សាត់អណ្តែត, សាត់ព្រាត់, សំណាត់សាត់តាមខ្សែទឹក... ។

នៅខេត្តពោធិ៍សាត់មានទីពិឃាតសត្វមួយ គេយកសាប់សត្វទាំងនោះទៅលក់ឯផ្សារឲ្យបណ្តាជនគង់ក្រុង ។

## សប់ - សប្ត - សព - សព្វ

សប់= សប់ទឹក, សប់គង់, មនុស្សប្រសប់, បេះដប់ពុំស្មើទីង ប្រសប់មួយ...

សប្តឬសប្ត-សប្ត= យល់សប្ត, យល់សប្តិ៍, យល់សុបិន...

សព= បូជាសព ដឹកលស់សព លើកសព...

Websites: WatKhemaraRatanaram.org or WatKhmers.org



សព្វ= សព្វគ្រប់, សព្វសាយ ប្រសព្វមុខ ទឹកហូរប្រសព្វគ្នា...

លោកគ្រូព្រះសព លោកប្រសប់ការងារគ្រប់សព្វទាំងអស់ ការណ៍ក្រយ៉ាំងណាក្តី ក៏លោកដោះស្រាយបានស្រួលឥតទើសទាស់ឡើយ ពីយប់មិញខ្ញុំយល់សប្តិឃើញលោកនិមន្តមកវត្តវិញ ។

## សា - សារ

សា– កិ. សាកន្ទួល, សាស្រូវ, សាមកវិញ ដើរសាចុះសាឡើង ។ ន. ស្រូវសា, ផ្ទៀកសា (ដែលដុះពីគល់ឡើងវិញ) សាគ្រី (ក្ងា) ឈ្មោះបែកសា...

សារឬសារៈ= ខ្លឹមសារ, សរសេរសារផ្ញើទៅ (សំបុត្រ) ឥតសព្វ ឥតសារ សារព្រឹក្ស (ឈើមានខ្លឹម) សារគ្រា, ដំរីសារ, សារពាន្ធកាយ, សារពើ សារពេជ្រ, សារភាព...

ដំរីសារស្លាប់យកបង្អែរប៉ាំង លុះប៉ាំងមិនជិតក៏ខឹងប្រឡោតឈ្មោះដេរគេជិតខាងបែកសាយាមោ ។

Websites: WatKhemaraRatanaram.org or WatKhmers.org



## សុក - សុក្រ - សុខ

សុក=ន. សុកកូន, ទឹកប់សុក, បង្អូនប្រឆាក់ទងសុក...

សុក្រឬសុក្ក = ផ្កាយសុក្រ, ថ្ងៃសុក្រ...

សុខ=គុ. សុខសប្បាយ, សុខក្សេមក្សាន្ត, សុខសាន្ត, សុខទុក្ខ ។

កូនលោកកើតពីថ្ងៃសុក្រ អាចារ្យនឹងបង្គាប់ឲ្យយកសុកទៅកប់ខាងទិសនិរតី ដើម្បីឲ្យទារកនឹងមាតាបានសេចក្តីសុខសប្បាយ អាយុយឺនយូរថែមទាំងឲ្យឈ្មោះចៅសុខទៀតផង ។

## សូ - សូរ - សូរ្យ

សូ=ន.(ខ្សែមាសឬប្រាក់មានសណ្ឋានជាប្រវ៉ាក់) ខ្សែសូ...

សូរ= (សព្ទសម្លេង) សូរផ្គរ, សូរសព្ទ, សូរសៀង...

សូរ្យ=ន. (ព្រះអាទិត្យ) សូរ្យសែន (ពន្លឺព្រះអាទិត្យ) សូរ្យគ្រាស (ដំណើរដែលរាហូចាប់ឬបាំងព្រះអាទិត្យ) ។

កាលពីថ្ងៃអាទិត្យមុនមានសូរ្យគ្រាស គេបានវាយស្គរវាយជួងឮសូរ

Websites: WatKhemaraRatanaram.org or WatKhmers.org



ពង្រត់វត្ត ស្រីខ្លះពាក់គ្រឿងអលង្ការ មានចំហុយទឹនខ្សែសូជាដើម

ឥន្ទិយ ថ្វាយបង្គំសូរ្យគ្រាសនៅកន្លះមុខផ្ទះ ។

## សូន - សូន្យ

សូន = កិ. សូនរូបក្រមួន, សូនគុលិកា..... ។

សូន្យ = គុ. សូន្យសុង, សូន្យសោះ, លេខសូន្យ... ។

លោកមេឃុំ បាននិយាយទីងជាងស្មិតពីខមុន ឡើយកដីឥដ្ឋសូន

ធ្វើរូបហនុមានមួយ ឥឡូវនេះជាងនោះ ក៏បាត់សូន្យឈឹង ពុំមានដំណឹង

អ្វីសោះ ។

## សួ - សួរ - សួគ៌

សួ = កិ. សួស្ដី - សួស្ដានមួស្សី - សួព្រ៉ែត្រ....

សួរ = កិ. សួរនាំ - សួរដំណឹង - សួរមាត់សួរពាក្យ - សំនួរ...

សួគ៌ = ន. ទេវលោក - ឋានសួគ៌ - ផ្លូវសួគ៌... ។

លោកអាចារ្យសួរទៅអ្នកដឹកខាងថា ស្ដដែលអ្នកពល់ស្នាសួ

ទៅកាន់ឋានសួគ៌បាន គេទៅពឹងលើផ្លូវណា ធ្លើយថាទីពឹងផ្លូវធម៌ ។

Websites: WatKhemaraRatanaram.org or WatKhmers.org



## សំរាន្ត – សំរិត – សំរិទ្ធិ

សំរាន្ត = លោកសំរាន្ត ឬ លោកសម្រាន្ត – ជម្ងឺស្រាកស្រាន្ត ជាសុខសាន្ត...

សំរិត = (ធ្វើឲ្យស្អាតឲ្យបរិសុទ្ធ) – សំរិតសំរាំង – អង្ករសម្រិត...

សំរិទ្ធិ = (សេចក្ដីសម្រេច – ចំរើន) សំរិទ្ធិជ័យ – ផលសំរិទ្ធិ... ។

ចូលឯងសម្រាកបន្ដិចចុះ លុះដល់ម៉ែគាត់ក្រោកពីសម្រាន្ត ឯងយក ផលសំរិទ្ធិនេះដាក់អង្ករសំរិតឲ្យពេញទៅជូនគាត់កុំខាន ។

## ស្និត – ស្និទ្ធ – ស្នើ – ស្នើរ

ស្និត = ន. ស្និតបេក – ស្និតសិតបៃ – ស្និតស្នែន...

ស្និទ្ធ = (ស្រឡាញ់អស់ពីចិត្ត) មនុស្សស្និទ្ធនឹងគ្នា – ស្និទ្ធស្នាល ស្និទ្ធស្នេហ៍...

ស្នើ = (សួរឲ្យដឹងសិន) ស្នើការ – ទូលស្នើរ...

Websites: WatKhemaraRatanaram.org or WatKhmers.org



ស្ទើរ= (ស្រពាប់សន្លាត់) រើយកតាមស្ទើរ-មួមួយស្ទើរ-(មូពីរសន្ទឹក)...

មានសិស្សពីរនាក់ស្ងួតស្ងាល់ទឹងគ្នាណាស់ ពីល្ងាចមិញនាំគ្នាទៅចិញ្ចឹមស្ទិតស៊ិតថៃ រួចទិញបេកនួនមួយសុទ្ធតែទឹងមូដបស្ទើរយកទៅស្ទើការទឹងគេ ត្រែងបានសម្រេចដូចប្រាថ្នា ។

## ស្នា-ស្នារ-ស្នូរ-ស្នោះ

ស្នា= ន. ស្នាតាង-ស្នាក៏-ស្នាគម.....

ស្នារ= ស្នារតីឬស្មារ-មានស្នារតី-ស្នារណាទោស....

ស្នូរ= (កំណាញ់)-ស្នូរជន-ចិត្តស្នូរជន....

ស្នោះ= ស្នោះឆារ (ខ្ជិល)-ស្នោះសរ (សេចក្ដីកែកពាយ)-ស្នោះស្ត្រ....

បុរសដែលមកពីថៃសុក្រ មុខពា ស្នាគាង ស្នារតីរឹង ចិត្តស្នូរជនឥតមានសេចក្ដីស្នោះសរទឹងអ្នកជិតខាងឡើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org



## ស្រុស-ស្រុះ-ស្លេស្ម-ស្លេះ

ស្រុស= កិ. ស្រុសអន្ទក់ ស្រុសមាន់....

ស្រុះ= កិ.ស្រុះស្រួលគ្នា ស្រុះគ្នាដូចស្រមោច....

ស្លេស្ម= (ទឹករំអិលការចេញតាមបំពង់ក) ក្អកធ្លាក់ស្លេស្ម....

ស្លេះ= (ឈប់បន្អន់ទុក) ត្រូវស្លេះសេចក្ដីនេះទុកសិន... ។

ជីដូនចៅមាន គាត់ក្អកធ្លាក់ស្លេស្មមានឈាម កូនចៅគាត់ស្រុះគ្នាណាស់ ខ្លះរត់រកថ្នាំ ខ្លះរកស្លឹកឈើណាដែលគេដាក់យកមកស្ងោរ ឬស្រុសយកទឹកឲ្យគាត់ពិសាឲ្យបានបាត់ក្អក ។

## ហត្ថ-ហាត់-ហា-ហារ

ហត្ថ= ន. (ដៃ) - ហត្ថខ្នាត - មួយហត្ថ - ហត្ថកម្ម....

ហាត់= កិ. ហាត់គុន - ហាត់រៀន - ហាត់ប្រាណ...

ហា= កិ. ហាមាត់ លៀសហាលថ្ងៃហា...

Websites: WatKhemaraRatanaram.org or WatKhmers.org



ហារ = ចែក - លេខហារ - ជើងហារ ... ។

នៅសាលាហត្ថកម្ម មានហត្ថខាតគ្រប់យ៉ាងសំរាប់រស់ មានកន្លែងហាត់ប្រាណ មានបន្ទប់រៀនសំរាប់សិក្សាខាងអក្សរ ទិងលេខ បូក សង គុណ ហារ ។

ហោ - ហោរ

ហោ = ឈើគុសមួយហោ ដេរប្រយ័ត្នកុំឲ្យហោ (ជ្រួញ) . . .

ហោរ = (ហោរា) - កូតនៅហោរ ហោរនៅជាង . . .

មានហោរម្នាក់នៅខាងលិចហៅគ្រូវត្តយើង ល្បីឈ្មោះខាងទាយធុតណាស់ មនុស្សទៅមករកគាត់ហូរហែពុំសូវដាច់ទេ ។

ហួ - ហួត

ហួ = ន. (ពេទ្យ) - ពេទ្យហួ - ហួមើលជម្ងឺ - ហួដីរ ហួថាវ

(ហួចាស់ទុំ ជាគ្រូលើហួដំរីក្នុងពួកមួយ ១)

Websites: WatKhemaraRatanaram.org or WatKhmers.org



ហ្មត់= (អស់) – ភ្លើងឆេះហ្មត់, ហ្មត់ចត់ (ត្រឹមត្រូវ)

ហ្មត់ហ្មង (ឥតសៅហ្មងឬសុទ្ធសុទ្ធ) ។

ហ្មថាវបញ្ញត្តទៅហ្មទាំងឡាយឲ្យធ្វើការដោយហ្មត់ចត់ កុំធ្វេសប្រហែសឲ្យសោះ បើមានហេតុផ្សេង ៗ ត្រូវរត់រកពេទ្យហ្មយ៉ាងប្រញាប់ ៗ

## ពាក្យទំនឹមទំនៀមបុរាណ

- ចូលស្ទឹងតាមបត់
- អណ្ដាតជាអាទិ៍កន្លង អស់ទ្រព្យធនផងពីព្រោះអណ្ដាត
- ដឹងឆ្លើយផ្សិតផង កូនគ្ងផ្សិតមេបា
- ឈើពុកកុំអង្គុយលើ
- អូសទូកកុំឲ្យលំអាន ចាប់ត្រីបានកុំឲ្យល្អក់ទឹក
- ស្រឡាញ់ខ្លួនឲ្យស្ងួនចំណី ស្រឡាញ់ស្រីឲ្យស្ងួនចិត្ត
- ស្រឡាញ់មេរំពេដល់កូន
- ឈើផ្លែច្រើនចាញ់ស្លឹក ត្រីច្រើនទឹកល្អក់ពុំថា
- កាន់កពស់កាន់ឲ្យខ្ជាប់ ក្រែងត្រឡប់ខាំឯប្រាណ

Websites: WatKhemaraRatanaram.org or WatKhmers.org



– ទឹកហូរមិនដែលហត់ មនុស្សស្បថកុំឲ្យជឿ

– ត្រីមួយត្រក ស្អុយតែមួយ ស្អុយទាំងអស់

– ពងមាន់កុំជល់នឹងថ្ម

– ធ្ងន់នៅថ្មក្រ នៅគ្គី

– ប្រាជ្ញពុំស្មើប្រឹប ផាក់ស្ញឹកគ្រៀកខ្លួប ពុំស្មើខ្សៀមខ្សឹម

– គយដេកជាស់គយឲ្យអង្ករ

– កុំបំពត់ស្រឡៅ កុំប្រដៅមនុស្សខ្លូប

– ទំពាំងស្នងឫស្សី

– ដំរីជុះកុំជុះតាមដំរី

– ដើរឲ្យមានបី ស្រដីឲ្យមានបួន

– សូវបង់ប្រាក់មួយថង់ កុំឲ្យបង់ពាក្យ

– ផ្ទះធំស្រណុក ព្រោះលក្ខណ៍ស្រីជា

## ហ្វូង – ល្បួង

ហ្វូង = ន. (ព្រះរាជា)= ហ្វូងយាន – ហ្វូងទបពជ ហ្វូងសេនា
នុរក្ស (សំរាប់ជាងព្រះ) ហ្វូងព្រះផាង... ។

Websites: WatKhemaraRatanaram.org or WatKhmers.org



ល្បង= កិ. លួងលោម លួងលួងឲ្យស្រួលចិត្ត... ។

ព្រឹកស្អែកនេះ ហ្វូងទីងយាងចេញប្រមាណរង្វាន់ដល់ពួកក្រុមពិជ័យសង្គ្រាម ។ ហ្វូងស្តេចចូលទៅក្នុងព្រះមហាដំណាក់ លួងលោមព្រះមហេសីមុននឹងចេញទៅក្រសាលឯព្រៃព្រឹក្ស ។

## អ្ន_អន្ន_អំណាន_ល្អ_លំអ

អ្ន= ន. ប្រាយអ (កំបោរថ្ម ខ្ចប់លាយទឹក)–ផ្ទុំអ (ប៉ុបបុស)...

អន្ន= កិ. (មានអំណរ) អរគុណ–អរបានទ្រព្យ...

អំណាន= ន. (សទិគ្គអរ) មានអំណរ...

ល្អ= គុ. ចិត្តល្អ–រូបល្អ–អំពើល្អ...

លំអ= ន. (សេចក្ដីល្អ)–លំអរូប...

ជាងយកកំបោរថ្មទីងដីខ្ចប់លាយទឹកធ្វើជាប្រាយអ ហើយយកស៊ីម៉ង់ត៍លាយបញ្ចូលខ្លះទៀតឲ្យបានជាប់ល្អ ដើម្បីឲ្យម្ចាស់ផ្ទះត្រេកអរនឹងការរបស់ជាង ។

Websites: WatKhemaraRatanaram.org or WatKhmers.org


## អប្ប-អ័ព្ទ-អាប់

អប្ប= ម.ថ. អប្បៈ (តិច-ស្តួចស្តើង) អប្បទ្រព្យ-អប្បបញ្ញា
អប្បលាភ...

អ័ព្ទ ឬ អ័ព្រ = (ពពកខាប់) - ចុះអ័ព្ទ-ងងឹតអ័ព្ទ-ធូលីហុយ
អ័ព្ទ អ័ព្ទអួ ...

អាប់= (ដែលអន់ឬតិចពន្លឺ)-អាប់គំនិត-អាប់ជាតិ-អាប់
ប្រាជ្ញា (ខ្សោយ) -អាប់មុខ-អាប់រស្មី...

ព្រឹកមិញចុះអ័ព្ទពេញទន្លេ នាំឲ្យអ្នកអុំឬបើកទូកអាប់ប្រាជ្ញា នឹង ងងឹតអ័ព្ទនោះ រកផ្លូវស្ទើរតែពុំឃើញ ។

## អសារ-អាសន្ន-អាសា

អសារ= (ដែលឥតខ្លឹម-ប្រយោជន៍-ឥតអំពើ)-របស់
អសារឥតការ-សំដីអសារឥតការ...

អាសន្ន= (ជិត) -ភ័យអាសន្ន (ភ័យជិត) មានអាសន្ន-
បណ្ដោះអាសន្ន... ។

Websites: WatKhemaraRatanaram.org or WatKhmers.org


អាសា=ន. បំណាន់-សង្ឃឹម:មានអាសា ។ អាសា-ប្រើជា: ន. ឬគុ.

បានសេចក្ដីថា «ការជួយឈឺឆ្អាលដោយស្ម័គ្រចិត្ត:យកអាសាគេ»។

កាលពីខែដាច់ទៅ គាត់មានអាសន្ន បានតែមកខ្ចីប្រាក់ខ្ញុំមួយរយរៀល ខ្ញុំក៏យកអាសាគាត់ ដល់គ្រប់សន្យាហើយ ខ្ញុំទៅទារខ្ទាបខ្ចប់ប្រាក់អសារឥតការ គាត់ថាកុំអាលអាសន្នពេក អញមិនរត់ទៅណាទេ ។

**អាទិ-អត្ថ-អារ្យ**

អាទិឬអាទ៍= ម.ថ.អាត.ន. (ដើម-ដើមដំបូង) នាំអាទ៍ (នាំផ្ដើមមុន)-ធម្មតាអ្នកជាជាតិ កាលគេអាទ៍ ឲ្យគិតគូរ កុំខ្ជិលបេដេកទទូរ ដល់ថ្ងៃរះពេញពន្លឺ ។

អត្ថ= ម.ថ.អ័ត-ន. (ប្រយោជន៍-សេចក្ដី-ពាក្យប្រែ ស្រាយ-រឿងហេតុ) ស្គាល់អត្ថ (ស្គាល់សេចក្ដី)- រៀនអត្ថ (រៀនសេចក្ដីអធិប្បាយ)...

អារ្យ= (អរិយ) (ប្រសើរ ត្រឹមត្រូវ-សុភាព)=អរិយធម៌ឬ- អារ្យធម៌ (ធម៌ដែលនាំឲ្យចំរើន សេចក្ដីសុខចំរើន)...

Websites: WatKhemaraRatanaram.org or WatKhmers.org



រៀនអត្ថហ្មត់ចត់ណាស់ ចេះធម៌អាថ៌ក៏ជ្រៅជ្រះណាស់ដែរ តែនៅភ្លាត់ម្ដងៗ ។

## បារម្ភ – អារម្មណ៍

បារម្ភ=(ការផ្ដើម–សេចក្ដីផ្ដើម–ការទាំអាទ៌) ខ្ញុំមានបារម្ភខ្លាំងនឹងការណ៍នោះអ្នកកុំបារម្ភឲ្យសោះ ខ្ញុំធានាជួយ ឲ្យខានតែបាន ។

អារម្មណ៍= (គ្រឿងតោងរបស់ចិត្ត–គំនិត–ការដឹង) អារម្មណ៍មិនល្អមិនទៀង – ចាប់អារម្មណ៍ (ចាប់ចិត្ត អធ្យាស្រ័យ...) ។

អ្នកកុំបារម្ភនឹងការណ៍ដែលអ្នកពឹងខ្ញុំឲ្យជួយគិតគូរនោះ គេនឹងសម្រេចដូចចិត្តអ្នកប្រាថ្នា ប៉ុន្តែអ្នកកុំទាស់អារម្មណ៍នឹងកិរិយារបស់អ្នកត្រូវសន្ដោសប្រោសប្រណីពីព្រោះគ្នាបានជាប្រព្រឹត្តហួសទៅហើយ ។

## អាប – អាបម៌

អាប=. (ហ៊ាន – ធ្វើបាន – មិនរួញរា) – អាចធ្វើបាន – អាចជាបាន... ។

Websites: WatKhemaraRatanaram.org or WatKhmers.org



អាប់= ម.ជ. អាច់ – (អាហារចាស់) – អាចម៍ម – អាចម៍សត្វ...

អាចម៍ល័ខអាចក្ឈួរក្ឈាប់ស៊ីផ្សេង ៗ បាន ដូចជាមៀនកាំបិត កណ្ដ ជាដើម មិនអាចទឹងរគ្គោះឆាយទេ ។

## អា – អារ – វអា

អា= បុរិសសព្វនាម ជាពាក្យតាបឥតគួរសម – អាណា អានេះ – អាឯង...

អា = គុ. ស្រីអា – មេគោអា (ឥតកូន)...

អារ= កិ. កាត់ – បំបែក ៗ អារឈើ – អាររំលំ – អារប្រៀក

វអា= កិ. ឬ គុ. – ពេញព្រាន់ខ្លាំង ៗ ចិត្តរអា – ខ្ញុំរអា- ហើយ រអាសាច់ (ព្រាន់សាច...) ។

អាពារនេះគេធ្វើខ្លួនទោសវ៉ាច្រើនលើកមកហើយ រួ នរអាសេ ឥឡូវនេះខ្ញុំមិនហ៊ានអារកាត់សេចក្ដីនេះទេ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ខេមរភាសា

ង. ឈុំ

អតីតចាងហ្វាងសាលារៀនព្រះអង្គអេង ([illegible])

# ពាក្យ

## ភាសា–អក្ខរាវិរុទ្ធរបស់ពាក្យ

បោះពុម្ពលើកទី ៥

ការផ្សាយរបស់

បណ្ណាគារ

រស្មីកម្ពុជា

កម្មសិទ្ធិ

TOUS DROITS RESERVES

ព. ស. ២៥០០ គ. ស. ១៩៥៧

Websites: WatKhemaraRatanaram.org or WatKhmers.org

តម្លៃ ១៥រ